ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

២៩-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០៣៥ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ៥៩២

២-ព្រះរាជក្រឹត្យ

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៣ ស្ដីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងយុត្តិធម៌ ៥៥១

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៤ ស្ដីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងព័ត៌មាន ៥៥៥

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៥ ស្ដីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល [illegible]ាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិល រ[illegible]ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ៥៦០

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៦ ស្ដីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងកិច្ចការនារី ៥៦៧

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៧ ស្ដីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ៥៧១

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១០-០១-២០០៧ -អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តសៀមរាប ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ៥៨៧

១០-០១-២០០៧ -អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៩៨

១០-០១-២០០៧ -អនុក្រឹត្យលេខ ០៦ អនក្រ.បក ស្តីពីការបន្ថែមប្បៀវត្សជូនកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និង យុទ្ធជនពិការ ៦០០

១០-០១-២០០៧ -អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦០២

១១-០១-២០០៧ -អនុក្រឹត្យលេខ ៣៥ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ៦០២

១១-០១-២០០៧ -អនុក្រឹត្យលេខ ៣៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៦០៥

១១-០១-២០០៧ -អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៧

១១-០១-២០០៧ -អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៨

១១-០១-២០០៧ -អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦០៩

១១-០១-២០០៧ -អនុក្រឹត្យលេខ ៤០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦១០

២_សេចក្តីសំរេច

១២-០១-២០០៧ -សេចក្តីសំរេចលេខ ០២ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៦១២

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣០-១២-២០០៦ -សារាចរលេខ ០១៦ សហវ ស្តីពីការណែនាំលើការអនុវត្តន៍ថវិកាឆ្នាំ ២០០៧ ៦១៣

២៩-១២-២០០៦ -សេចក្តីណែនាំលេខ ០១១ សហវ ស្តីពីការបំពេញបន្ថែមលើអាណត្តិបើកប្រាក់ ការកត់ត្រាអចលនកម្មកំពុងដំណើរការ ការបើកប្រាក់រដ្ឋទេយ្យបុរេប្រទាននៅដើមការិយបរិច្ឆេទ និង ការកត់ត្រាចំណាយថវិកា តាមកម្មវិធីទាក់ទងមាតិកាគណនីថ្មី ៦២៨

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៩៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាថេល ខូ អិលធីឌី** ៦៣២

១០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ៉ាសាថី ហូលឌីង អិលធីឌី** ៦៣៤

១០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដូលីណា គ្រីប ខូ អិលធីឌី** ៦៣៦

១២-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈូរ៉ស & ត្រេឌីង ខមភេនី លីមីធីត** ៦៣៨

គ

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាកា តេត្រូលៀម អឹមផត អិចផត លីមីធីត** ៦៣៩

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អិន ខេ** ៦៤១

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេមីអឹស ត្រាវែល & ធួរ** ៦៤៣

១៧-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យៀក ស៊ុន អ៊ិនវេសមេន** ៦៤៥

ព្រះរាជក្រម

នស/រកម/១២០៦ /០៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់

ស្តីពី

ហិរញ្ញវត្ថុសម្រាប់

ការគ្រប់គ្រងឆ្នាំ ២០០៧

ជំពូកទី ១

បទប្បញ្ញត្តិស្តីពីវិសោធនកម្ម

ផ្នែកទី ១

បទប្បញ្ញត្តិស្តីពីការកែប្រែមាត្រាមួយចំនួន នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

មាត្រា ១.–

មាត្រា ៦ មាត្រា ៧ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ មាត្រា ១៧ មាត្រា ២៦ មាត្រា ៣៥ មាត្រា ៣៩ មាត្រា ៤២ មាត្រា ៥៤ និងមាត្រា ៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ព្រមទាំងត្រូវបានកែប្រែដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ត្រូវបានកែប្រែដោយបទប្បញ្ញត្តិដូចតទៅ :

មាត្រា ៦.–ថ្មី

ធនធានអចិន្ត្រៃយ៍របស់ថវិការដ្ឋមាន ចំណូលជាប្រក្រតី និងចំណូលជាមូលធន ។

- ចំណូលជាប្រក្រតី ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :
  - ក្រុមទី ១ : ចំណូលពិត
    - -ប្រភេទទី ១ : ចំណូលសារពើពន្ធ
    - -ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ
  - ក្រុមទី ២ : ចំណូលតាមដីកា
    - -ប្រភេទទី ៣ : ចំណូលតាមដីកា

- ចំណូលជាមូលធន ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :
  - ក្រុមទី ១ : ចំណូលពិត
    -ប្រភេទទី ១ : ចំណូលពីប្រភពផ្ទាល់
    -ប្រភេទទី ២ : ចំណូលពីប្រភពខាងក្រៅ
  - ក្រុមទី ២ : ចំណូលតាមដីកា
    -ប្រភេទទី ៣ : ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុអាចលំអិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៧.-ថ្មី

ចំណូលសារពើពន្ធរួមមានចំណូលសារពើពន្ធក្នុងប្រទេស និង ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ។

ចំណូលមិនមែនសារពើពន្ធរួមមាន ផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនលើការលក់ ឬ ជួលទ្រព្យសម្បត្តិ និង សេវា ផលពីការពិន័យ ការឧបត្ថម្ភ-អំណោយ ផលហិរញ្ញវត្ថុ និងផលពិសេស ។

ចំណូលជាមូលធនរួមមានអចលកម្មហិរញ្ញវត្ថុផ្សេងៗ ឧបត្ថម្ភកធនវិនិយោគ និងការខ្ចី ។

មាត្រា ១៣.-ថ្មី

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណាយជាប្រក្រតី និង ចំណាយជាមូលធន ។ បន្ទុកនេះត្រូវបានចែកជាក្រុម និង ជាប្រភេទ ។

មាត្រា ១៤.-ថ្មី

ចំណាយជាប្រក្រតីរបស់ថវិកា ត្រូវបានបែងចែកជា ២ ក្រុម និង ៦ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  -ប្រភេទទី ១ : មធ្យោបាយសេវា
  -ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ
  -ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ

-ប្រភេទទី ៤ : ចំណាយផ្សេងៗ

ក្រុមទី ២ : ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក

-ប្រភេទទី ៥ : ចំណាយតាមដីកា

-ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក

ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជា ជំពូក គណនី អនុគណនី និងជាយ-ថាហេតុ អាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៥.–ថ្មី(២)

ចំណាយជាមូលធននៃថវិកាគឺសំរាប់ការអនុវត្តន៏កម្មវិធី ការអនុវត្តន៏គំរោងវិនិយោគ ការចូលរួមភាគកម្ម និង ការទូទាត់បំណុល ។ ចំណាយជាមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត

-ប្រភេទទី ១ : ការទូទាត់ប្រាក់ខ្ចី

-ប្រភេទទី ២ : អចលកម្ម

- ក្រុមទី ២ : ចំណាយតាមដីកា

-ប្រភេទទី ៣ : ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយ-ថាហេតុ អាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលអនុវត្តដោយមិនឆ្លងកាត់បរិបថថវិកាពេញលេញ គឺជាឥណទានមានលក្ខណៈចាំន់ស្ថាន ហើយពុំអាចធ្វើជាកម្ម-វត្ថុនៃនិយ័តភាពទៅប្រភេទថវិកាណាមួយផ្សេងទៀតបានឡើយ ។

មាត្រា ១៧.–ថ្មី(២)

ឥណទានថវិកាដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ត្រូវបានបែងចែកលំអិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និង គោលដៅនៃឥណទានថវិកា ។

ឥណទានទាំងនេះអាចធ្វើជាកម្មវត្ថុសំរាប់ការរៀបចំថវិកាតាមកម្មវិធី និងការប្រមូលផ្តុំតាមវិស័យផងដែរ ។

ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំណាយជាប្រក្រតីនៃប្រភេទ ២ "បន្ទុកហិរញ្ញវត្ថុ" និងប្រភេទ ៦ " ចំណាយមិនបានគ្រោងទុក " មិនត្រូវបានបែងចែកឱ្យទៅក្រសួង ឬ ស្ថាប័នសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។

ឥណទាននេះទុកសំរាប់សងការប្រាក់នៃប្រាក់ខ្ចី ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងឥណទានត្រៀមបំរុងសំរាប់ចំណាយផ្សេងៗលើមុខសញ្ញាដែលកើតឡើងជាយថាហេតុ ។

ឥណទានត្រៀមបំរុង ត្រូវបានអនុញ្ញាតសំរាប់ការចំណាយទាំងឡាយណា ដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់នៅពេលដែលឥណទាននោះត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបំរុងទាំងនេះតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រភេទ ១ នៃចំណាយជាមូលធន គឺសំរាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និងពីក្រៅប្រទេស និង មូលបត្រផ្សេងៗ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និងមូលបត្រផ្សេងៗ ។

មាត្រា ២៦-ថ្មី(២)

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំនីមួយៗ តាមប្រតិទិនដូចខាងក្រោមនេះ :

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែ មីនា ដល់ខែ ឧសភា)

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម

ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិ សំរាប់ការអភិវឌ្ឍន៍ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់រដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង អង្គភាពក្រោមឱវាទ ដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅកម្មវិធី និង ផែនការសកម្មភាពជាអាទិភាពរបស់ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់វិស័យ និង គោលនយោបាយជាតិសំរាប់ការអភិវឌ្ឍន៍ ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

ការរៀបចំគម្រោងថវិកា (ពីខែ មិថុនា ដល់ខែ កញ្ញា)

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ដោយបញ្ជាក់ជូននូវទំរង់បែបបទ និងនីតិវិធីនៃការរៀបចំគំរោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញ និង ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ហើយផ្ញើជូនក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ដើម្បីរៀបចំគំរោងចំណូល-ចំណាយថវិកាលំអិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណូល-ចំណាយថវិកាលំអិតរបស់ខ្លួន សំរាប់រដ្ឋបាលកណ្តាល មន្ទីរជំនាញ ខេត្ត-ក្រុង និង អង្គភាពក្រោមឱវាទ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគំរោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គំរោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគំរោងចំណូល-ចំណាយថវិការបស់ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័ន ព្រមទាំងអភិបាលគ្រប់ខេត្ត-ក្រុង មកពិភាក្សាការពារគំរោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគំរោងចំណូល-ចំណាយថវិកាទាំងនោះឱ្យសមស្របតាមបទប្បញ្ញត្តិនៃការណែនាំ ដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និង បង្កើនចំណូលឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការបូកសរុប ដើម្បីធ្វើតុល្យភាពចំណូល-ចំណាយថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

ការអនុម័តថវិកា (ពីខែ តុលា ដល់ខែ ធ្នូ)

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និង ដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទីមួយនៃខែ ធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

មាត្រា ៣៥--ថ្មី

គំរោងច្បាប់ហិរញ្ញវត្ថុចែកចេញជាពីរផ្នែក ។ ផ្នែកទី ១ ច្បាប់អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានសាធារណៈ និង កំណត់ធនធានទាំងនោះជាទឹកប្រាក់សរុប ។ ច្បាប់បានកំណត់ទិសដៅ និង មធ្យោបាយអនុវត្តចំពោះចំណាយជាមូលធន ។ ច្បាប់បានកំណត់នូវឥណទាន ត្រូវផ្តល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិកាទូទៅ និង គណនីពិសេសរបស់រតនាគារ ។ ច្បាប់រួមមានបទប្បញ្ញត្តិទាំងឡាយដែលទាក់ទងដល់ចំណូលសារពើពន្ធ និង ទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត ។ ផ្នែកទី ២ រួមមានតារាងកំណត់ចេញជាក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ដែលទាក់ទងដល់ចំណូលជាប្រក្រតីនៃថវិកាទូទៅ ។ ច្បាប់មានគំរោងចំណាយជាប្រក្រតីរបស់ថវិកាទូទៅ បែងចែកទៅតាមក្រសួង និង អង្គភាពសាធារណៈ

ប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយដែលបានអនុម័ត ។ ច្បាប់បាន កំណត់ទិសដៅ និង មធ្យោបាយអនុវត្តសំរាប់ចំណាយជាមូលធននៃថវិកា និង កម្មវិធីឥណទាន និង បែងចែកចំណាយជាមូលធនទៅតាមក្រសួង និង អង្គភាពសាធារណៈប្រហាក់ប្រហែល ជាជំពូក ដែលចែកចេញជាឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ ច្បាប់កំណត់បញ្ជី គណនីពិសេសរបស់រតនាគារដែលមានលក្ខណៈរដ្ឋបាល និង កំណត់គណនីពិសេសនីមួយៗ នូវចំនួនទឹកប្រាក់ចំណូល និង ចំនួនទឹកប្រាក់ចំណាយ ។

មាត្រា ៣៩.-ថ្មី

ការបែងចែកលំអិតនៅក្នុងជំពូក ជាគណនី និង អនុគណនីនៃឥណទានទាំងឡាយ ត្រូវ ប្រព្រឹត្តទៅដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៤២.-ថ្មី

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយ នៅក្នុងជំពូកតែមួយ ត្រូវបានអនុញ្ញាតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៥៤.-ថ្មី

រដ្ឋកាន់គណនេយ្យចំណូល-ចំណាយថវិកា និង គណនេយ្យទូទៅនៃកិច្ចប្រតិបត្តិការ ទាំងមូល ។ គណនីរបស់រដ្ឋ ត្រូវមានភាពទៀងទាត់ប្រាកដប្រជានៃបេតិកភ័ណ្ឌ និង ស្ថានភាព ហិរញ្ញវត្ថុ ។

គណនេយ្យទូទៅរបស់រដ្ឋ ត្រូវផ្អែកលើគោលការណ៍កត់ត្រាទុកមុននូវសិទ្ធិ និង កាតព្វកិច្ចប្រតិបត្តិការទាំងឡាយដែលជាប់ពាក់ព័ន្ធដោយមិនផ្អែកលើកាលបរិច្ឆេទបើកផ្តល់ ឬ ទទួលចំណូល ។

មាត្រា ៦០.-ថ្មី

ប្រតិបត្តិការដែលបង្ហាញដោយសេចក្តីព្រាងនៃច្បាប់ស្តីពីការទូទាត់ថវិកា ត្រូវបានលាត ក្នុងតារាងទាំងឡាយដែលបង្ហាញ :

១-ចំពោះចំណាយនៃថវិកាទូទៅ : ការគ្រោងទុកដើមដំបូង ការអនុញ្ញាតថ្មីនិង បញ្ជាចំណាយ បែងចែកតាមក្រសួង ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

២-ចំពោះចំណូល : ការគ្រោងទុកដើមដំបូង ព្រមទាំងការកែប្រែ និង ការប្រមូល ដែលញែកតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

៣-ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និង ចំណាយ និងការកែប្រែ ដែលបានធ្វើប្រសិនជាមាន ជាមួយនឹងសមិទ្ធិកម្មសំរាប់ថវិការបស់រដ្ឋបាល សាធារណៈនីមួយៗ ។

មាត្រា ២.-

ការអនុវត្តន៍ថវិកា និង ការទូទាត់ថវិកាសំរាប់បណ្តាឆ្នាំមុនឆ្នាំ ២០០៧ ត្រូវអនុវត្តទៅ តាមមាតិកាថវិកា និង មាតិកាគណនេយ្យដូចដែលបានអនុម័តថវិកា ។ ការរៀបចំថវិកា ការ អនុវត្តន៍ថវិកា និង ការទូទាត់ថវិកាសំរាប់ឆ្នាំ ២០០៧ និង ឆ្នាំបន្តបន្ទាប់ត្រូវធ្វើទៅតាមមាតិកា ថវិកា និងមាតិកាគណនេយ្យដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ។

ផ្នែកទី ២
បទប្បញ្ញត្តិស្តីពីពន្ធដារ

មាត្រា ៣.-

មាត្រា ៣០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដូចខាង ក្រោម :

មាត្រា ៣០.-ថ្មី

មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារ តាមទីក្រុង និង តាមតំបន់នីមួយៗ ដែល វាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិន បានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំប្រមូលពន្ធ ។

មាត្រា ៤.-ថ្មី

មាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម៖

មាត្រា ៧.-ថ្មី

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល និង សួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង ។ ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬ ទ្រព្យវិនិយោគ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម ។ និយមន័យនៃពាក្យ"អចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ទ្រព្យវិនិយោគ ការសម្រេចបាន" ព្រមទាំងការកំណត់មូលដ្ឋានគិតពន្ធ វិធាន និងនីតិវិធីនៃការប្រមូល ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៥.-

រូបវន្តបុគ្គល និង នីតិបុគ្គល ដែលប្រកបសេវាកម្មវាយតម្លៃ និង ជួញដូរអចលនទ្រព្យ ត្រូវមានវិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ វិធាន និងនីតិវិធី ក្នុងការចេញវិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្នែកទី ៣

បទប្បញ្ញត្តិស្តីពីការកែប្រែមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

មាត្រា ៦.-

មាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ត្រូវបានកែប្រែដូចតទៅ :

មាត្រា ១៧.-ថ្មី

ចំណូលនៃថវិកាខេត្ត-ក្រុងរួមមានចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ដែលបានផ្ទេរពីថវិការដ្ឋ ឬ បង្កើតឡើងដោយច្បាប់ដោយឡែក ។ ខេត្ត-ក្រុងគ្មានសិទ្ធិសំរេចក្នុងការខ្ចីទេ ។

១-ត្រូវបានផ្ទេរពីថវិការដ្ឋទៅថវិកាខេត្ត-ក្រុង នូវចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដូចតទៅ :

ក/ចំណូលសារពើពន្ធ :

-ពន្ធប្រថាប់ត្រា

-ពន្ធលើដីធ្លីមិនបានប្រើប្រាស់

-អាករសំរាប់បំភ្លឺសាធារណៈ (អាករបន្ថែមលើស្រា និងបារី)

-អាករលើការស្នាក់នៅ

-ពន្ធសត្តឃាដ

-ពន្ធប៉ាតង់

-ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

ខ/ចំណូលមិនមែនសារពើពន្ធ :

-សម្បទានពីរ៉ែ

-ការជួលកន្លែងលក់ដូរក្នុងទីផ្សារ

-ចំណូលពីភាស៊ីផ្សារ

-ចំណូលពីចំណតរថយន្ត

-ចំណូលពីចំណតជលយាន

-ចំណូលពីសត្តឃាដដ្ឋាន

-ចំណូលពីកំពង់ចំលង

៚

-ចំណូលពីកន្លែងប្រមូលផ្តុំ ដើម្បីបែងចែកនូវផលិតផលដោយខ្សែក (ត្រី ផ្លែឈើ បន្លែ.....)

-ផលទុននៃរដ្ឋាករទឹក

-ផលទុននៃការផ្គត់ផ្គង់អគ្គិសនី

២-មាតិកានៃចំណូលផ្ទាល់ពីចំណូលសារពើពន្ធ សំរាប់ជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ត្រូវបង្កើតឡើងដោយច្បាប់ដោយឡែក ។

៣-មាតិកានៃចំណូលផ្ទាល់ពីចំណូលមិនមែនសារពើពន្ធសំរាប់ជាគុណប្រយោជន៍របស់ខេត្ត-ក្រុង មានដូចតទៅ :

ក-ចំណូលពីការប្រើអំណាចរដ្ឋបាល របស់ខេត្ត-ក្រុង (ទម្រង់ការរដ្ឋ-បាលអនុញ្ញាតរដ្ឋបាល......)

ខ-ចំណូលពីសេវាសាធារណៈរបស់ខេត្ត-ក្រុង (សេវាផ្ទាល់សេវាសហ-ប្រតិបត្តិការ........)

ចំណូលទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមការឯកភាពរបស់ក្រសួងពាក់ព័ន្ធ ដែលនឹងត្រូវបែងចែកជាតារាងចំណូលជាអតិបរមា ។

គ-ផលទុននៃទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ខេត្ត-ក្រុង

ប្រភេទចំណូលដូចបានចែងក្នុងចំណុចទី ១ ទី ២ និងទី ៣ ខាងលើត្រូវបានបែងចែកជាជំពូក គណនី និងអនុគណនី ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ១៨.-ថ្មី

គំរោងថវិការបស់ខេត្ត-ក្រុង ត្រូវបានរៀបចំឡើងដោយអភិបាលខេត្ត-ក្រុង ទៅតាមនីតិវិធី ដែលបានកំណត់ដោយសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នៅសប្តាហ៍ទី ១ ខែ មិថុនា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ញើជូនខេត្ត-ក្រុង នូវសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកានៃឆ្នាំបន្ទាប់ ដើម្បីខេត្ត-ក្រុង រៀបចំគំរោងចំណូល-ចំណាយថវិការបស់ខ្លួន ។

គំរោងថវិការបស់ខេត្ត-ក្រុង ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា នៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុ ដែលបង្ហាញអំពីការវិភាគគោលដៅនៃកម្មវិធី និងចរិតលក្ខណៈនៃថវិកានោះ ។

គំរោងថវិការបស់ខេត្ត-ក្រុងទាំងអស់ គឺជាកញ្ចប់ថវិកាមួយ ដែលត្រូវបញ្ជូនមកសុំរដ្ឋសភាពិនិត្យអនុម័តយល់ព្រមក្នុងក្របខ័ណ្ឌថវិកាទូទៅរបស់រដ្ឋ និងត្រូវរក្សានូវតុល្យភាពសេដ្ឋកិច្ចជាមូលដ្ឋាន ។ ការបែងចែកកញ្ចប់ថវិកានេះទៅតាមខេត្ត-ក្រុងនីមួយៗត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

ជំពូកទី ២
ចំណូល_ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

មាត្រា ៧._

ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ ២០០៧ ឱ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលកុន និង ចំណូលនានា ព្រមទាំងធ្វើឱ្យសំរេចនូវអំណោយ មូលនិធិបដិភាគ និង ធនធានបានមកពីការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង “ក” ដែលភ្ជាប់មកជាមួយច្បាប់នេះក្នុងទឹកប្រាក់សរុបចំនួន ៤.៦២២.៣០៥,៥ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណូលចរន្ត.............................៣.២៥២.១៧២,៥ លានរៀល

-ចំណូលជាមូលធន.......................១.៣៧០.១៣៣ លានរៀល

+ ចំណូលជាមូលធនក្នុងប្រទេស...............៣០.០០០ លានរៀល

+ ចំណូលជាមូលធនក្រៅប្រទេស.........១.៣៤០.១៣៣ លានរៀល

មាត្រា ៨._

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសំរាប់

ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ស្មើនឹង ៤.៦២២.៣០៥,៥ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

-ចំណាយចរន្ត..............................២.៨៣៧.១៧២,៥ លានរៀល

-ចំណាយជាមូលធន...........................១.៧៨៥.១៣៣ លានរៀល

+ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស...៥៧៥.១៣៣ លានរៀល

+ ដោយមូលនិធិថវិកា[១] ....៣៤៥.០០០ លានរៀល

+ ដោយមូលនិធិទ្រទ្រង់ថវិកា................២៣០.១៣៣ លានរៀល

+ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់[២]

....១.១១០.០០០ លានរៀល

+ ការទូទាត់ប្រាក់កម្ចី..............................១០០.០០០ លានរៀល

មាត្រា ៩.–

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានថវិកាសំរាប់ចំណាយចរន្តរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ស្មើនឹង ២.៨៣៧.១៧២,៥ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទនៃថវិកា ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ១០.–

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋសំរាប់ការគ្រប់គ្រងពីឆ្នាំ ២០០៧ ដល់ ២០០៩ ត្រូវបានកំណត់ស្មើនឹង ៧.៤០៤.៨០៨ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគំរោង និង តាមឆ្នាំ ដូចមានចែងក្នុងតារាង "គ$_១$-គ$_២$-គ$_៣$" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

---

[១] រួមមានគំរោងវិនិយោគ ២២០.០០០ លានរៀល និង បរិភោគ ១២៥.០០០ លានរៀល

[២] វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ហើយចំនួនទឹកប្រាក់នេះមិនឆ្លងកាត់រតនាគារទេ ។

មាត្រា ១១.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សំរាប់ចំណាយជាមូលធននៃថវិការដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ដូចតទៅ :

-ឥណទានភ្ជាប់សន្យា..........................២.៥៨២.០៣៣ លានរៀល

-ឥណទានទូទាត់..............................១.៧៨៥.១៣៣ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ :

ក.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-ឥណទានភ្ជាប់សន្យា............................៥៧៥.១៣៣ លានរៀល

-ឥណទានទូទាត់.................................៥៧៥.១៣៣ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ :

-ឥណទានភ្ជាប់សន្យា.........................១.៩០៦.៩០០ លានរៀល

-ឥណទានទូទាត់..............................១.១១០.០០០ លានរៀល

គ. ការទូទាត់ប្រាក់កម្ចី :

-ឥណទានភ្ជាប់សន្យា............................១០០.០០០ លានរៀល

-ឥណទានទូទាត់.................................១០០.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង “ឃ” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ១២.-

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលបានរៀបចំឡើងដោយតារាង “ក” ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង “ខ” ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ :

ឯកតា:លានរៀល

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ	ចំនួនទឹកប្រាក់	ចំនួនលើស(+) /ឱនភាព(-)
I. ចំណូលក្នុងប្រទេស	៣.២៨២.១៧២,៥	
១. ចំណូលចរន្ត	៣.២៥២.១៧២,៥	
២. ចំណូលជាមូលធនក្នុងប្រទេស	៣០.០០០	
II. សរុបចំណាយថវិកា	៤.៥២២.៣០៥,៥	
១. ចំណាយចរន្ត	២.៨៣៧.១៧២,៥	
២. ចំណាយជាមូលធន[៣]	១.៦៨៥.១៣៣	
• វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស	៥៧៥.១៣៣	
+ ដោយមូលនិធិថវិកា	៣៤៥.០០០	
-គំរោងវិនិយោគ	២២០.០០០	
-បរិភោគ	១២៥.០០០	
+ វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា[៤]	២៣០.១៣៣	
• វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	១.១១០.០០០	
អតិរេកនៃថវិកាចរន្ត (I.១ -II.១)		+៤១៥.០០០
ឱនភាពសរុបនៃថវិកាទូទៅ (I-II)		-១.២៤០.១៣៣
III. ហិរញ្ញប្បទាននៃឱនភាព		+១.២៤០.១៣៣
១. ហិរញ្ញប្បទានក្រៅប្រទេស		+១.២៤០.១៣៣
- មូលនិធិទ្រទ្រង់ថវិកា		+២៣០.១៣៣
- មូលនិធិវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់		+១.១១០.០០០
- ការទូទាត់ប្រាក់កម្ចី		-១០០.០០០
២. ហិរញ្ញប្បទានក្នុងប្រទេស		
- ហិរញ្ញប្បទានធនាគារជាតិ		

[៣] មិនគិតការវិលល់ចំណូល ១០០.០០០លានរៀល ដែលមានកំណត់នៅក្នុងសារប័ត្រ III (ហិរញ្ញប្បទាននៃឱនភាព)

[៤] គំរោងទាំងអស់ត្រូវស៊ុំការយល់ព្រមចំណាយពីមេគួអភិវឌ្ឍន៍ជាមុន ។

ជំពូកទី ៣

ការខ្ចី និង ការធានារបស់រដ្ឋ

មាត្រា ១៣.-

អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេមានកំរិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលានអេសដេអ៊ែ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍នៃការខ្ចី និង ការធានានេះ ជូនរដ្ឋសភា និង ព្រឹទ្ធសភា រៀងរាល់៦ ខែ ម្តង ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឱ្យបោះផ្សាយប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ ដែលមានស្តុកចំនួន ១០០.០០០.០០០.០០០៛ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយនូវតំរូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ ល័ក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

មាត្រា ១៤.-

មិនអនុញ្ញាតឱ្យក្រសួង ឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬ ឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសង

៤

បំណុលតាមកាលកំណត់ ឬ តាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និង លក្ខខ័ណ្ឌទាំងឡាយ ដែលច្បាប់នេះបានកំណត់នោះទេ ។

ជំពូកទី ៤
ថវិការបស់ខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

មាត្រា ១៥.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់នេះ កញ្ចប់ថវិការួមនៃ ថវិការបស់ខេត្ត-ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

សរុបចំណូលថវិកា....................................១៦៨.៤០០ លានរៀល
- -សរុបចំណូលចរន្ត..............................១៦៨.៤០០ លានរៀល
  - + ចំណូលសារពើពន្ធ..........................៩៦.៤៥៤ លានរៀល
  - + ចំណូលមិនមែនសារពើពន្ធ....................២១.៩៤៦ លានរៀល
  - + ចំណូលឧបត្ថម្ភពីថវិការដ្ឋ....................៥០.០០០ លានរៀល
- -ចំណូលជាមូលធន.......................................០ លានរៀល
  - + ចំណូលជាមូលធនផ្ទៃក្នុង...............................០ លានរៀល
  - + ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ..........០ លានរៀល

សរុបចំណាយថវិកា...................................១៦៨.៤០០ លានរៀល
- -ចំណាយចរន្ត...................................១៣៤.៦២២ លានរៀល
- -ចំណាយជាមូលធន..............................៣៣.៧៧៨ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត-ក្រុងនីមួយៗក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកានេះជា ជំពូក គណនី និង អនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

មាត្រា ១៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ពរល.០៦១២.៥៥៥

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ : ៤៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ក"

ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ		២០០៧/២០០៦	
				២០០៦	២០០៧	កើន (+) / ថយ (-)	ភាគរយ
			សរុបរួមចំណូលថវិកា (I + II)	3.814.125,0	4.622.305,5	808.180,5	21,19%
			I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ)	2.956.325,0	3.512.305,5	555.980,5	18,81%
			ក្នុងនោះ ចំណូលក្នុងប្រទេស	2.812.720,0	3.282.172,5	469.452,5	16,69%
			ក. សរុបចំណូលចរន្ត (ក្រុ១+ក្រុ២)	2.780.720,0	3.252.172,5	471.452,5	16,95%
			ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)	2.780.720,0	3.252.172,5	471.452,5	16,95%
			ប្រភេទទី១: ចំណូលសារពើពន្ធ	2.224.053,0	2.682.000,0	457.947,0	20,59%
70			ចំណូលសារពើពន្ធក្នុងប្រទេស	1.495.949,0	1.857.540,0	361.591,0	24,17%
	700		ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន រូបវន្តបុគ្គល	52.600,0	72.200,0	19 600,0	37,26%
		7001	ពន្ធលើប្រាក់បៀវត្ស	37.600,0	52.000,0	14.400,0	38,30%
		7002	ពន្ធលើផលទុនទៃដីធ្លីផ្ទះសំបែង	15.000,0	20.200,0	5.200,0	34,67%
	701		ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន និតិបុគ្គល	152 000,0	267.700,0	115.700,0	76,12%
		7011	ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ	15.000,0	26.700,0	11.700,0	78,00%
		7012	ពន្ធលើប្រាក់ចំណេញសហគ្រាសឯកជន	137 000,0	241.000,0	104.000,0	75,91%
		7013	ពន្ធលើផលទុនទៃដីធ្លីផ្ទះសំបែង	0,0	0,0	0,0	
	702		ពន្ធទូទៅលើទ្រព្យសម្បត្តិ និង សេវា	814.342,0	976.650,0	162.308,0	19,93%
		7021	អាករលើផលរបរ របបផ្ទៃក្នុង សហគ្រាសសាធារណៈ	7,0	5,0	-2,0	-28,57%
		7022	អាករលើផលរបរ របបផ្ទៃក្នុង សហគ្រាសឯកជន	10.293,0	14.445,0	4.152,0	40,34%
		7023	អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង-សហគ្រាសសាធារណៈ	16.000,0	17 000,0	1.000,0	6,25%
		7024	អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង-សហគ្រាសឯកជន	221 000,0	322.560,0	101.560,0	45,95%
		7025	អាករលើតំលៃបន្ថែម-របបនាំចូល-សហគ្រាសប្រេងឥន្ធនៈ	152.145,0	151 620,0	-525,0	-0,35%
		7026	អាករលើតំលៃបន្ថែម-របបនាំចូល-សហគ្រាសផ្សេងៗទៀត	414.897,0	471.020,0	56.123,0	13,53%
	703		ពន្ធលើទ្រព្យសម្បត្តិបានកំណត់	419.419,0	449.800,0	30.381,0	7,24%
		7031	អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុង	68.600,0	70.900,0	2.300,0	3,35%
		7032	អាករពិសេសលើទំនិញមួយចំនួន របបនាំចូល សហគ្រាសប្រេងឥន្ធនៈ	0,0	113.650,0	113.650,0	!!!
		7033	អាករពិសេសលើទំនិញមួយចំនួន របបនាំចូល សហគ្រាសផ្សេងៗទៀត	350.819,0	265.250,0	-85.569,0	-24,39%
	704		អាករលើសេវាដែលបានកំណត់	53 088,0	83.800,0	30.712,0	57,85%
		7041	អាករលើកាស៊ីណូ	50.000,0	62.210,0	12.210,0	24,42%
		7042	អាករលើឆ្នោត	3.088,0	2.650,0	-438,0	-14,18%
		7043	អាករលើល្បែងភ្នាល់ផ្សេងៗ	0,0	1.140,0	1.140,0	!!!
		7048	អាករពិសេសលើសេវាមួយចំនួនផ្សេងៗទៀត	0,0	17.800,0	17.800,0	!!!
	708		ចំណូលសារពើពន្ធផ្សេងៗទៀត	4.500,0	7.390,0	2.890,0	64,22%
		7081	ពន្ធតែមប្រិ៍	1.700,0	2 490,0	790,0	46,47%
		7082	ការផាកពិន័យនិងទោសបញ្ញត្តិសារពើពន្ធ	2.800,0	4.900,0	2 100,0	75,00%

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ក"

ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ		២០០៧/២០០៦	
				២០០៦	២០០៧	កើន (+) / ថយ (-)	ភាគរយ
71			ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	728.104,0	824.460,0	96.356,0	13,23%
	710		ពន្ធ និង អាករលើការនាំចូល	671.759,0	748.870,0	77.111,0	11,48%
		7101	ពន្ធគយពីការនាំចូល	338.422,0	407.820,0	69 398,0	20,51%
		7102	កម្រៃយកមុនពីការងារគយក្នុងការនាំចូល	29.463,0	35.500,0	6.037,0	20,49%
		7103	ពន្ធគយលើផលិតផលតេលសិលា	171.533,0	176.480,0	4.947,0	2,88%
		7104	អាករបន្ថែមលើផលិតផលតេលសិលាសំរាប់ថែទាំផ្លូវថ្នល់	125.580,0	118.240,0	-7.340,0	-5,84%
		7105	ផលនៃការលក់ផ្ទៃគយ	965,0	180,0	-785,0	-81,35%
		7106	ពិន័យផ្សេងៗលើការនាំចូល	5.796,0	10.650,0	4.854,0	83,75%
	711		ពន្ធ និង អាករលើការនាំចេញ	56.345,0	75.590,0	19.245,0	34,16%
		7111	អាករលើការនាំចេញឈើ	2.508,0	3.195,0	687,0	27,39%
		7112	អាករលើការនាំចេញកៅស៊ូ	18.193,0	16.330,0	-1 863,0	-10,24%
		7113	អាករលើការនាំចេញផលិតផលកសិផលផ្សេងៗ	644,0	1.065,0	421,0	65,37%
		7114	កម្រៃគ្រប់គ្រងការនាំចេញ	35.000,0	55.000,0	20 000,0	57,14%
			ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ	556.667,0	570.172,5	13.505,5	2,43%
72			ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	58.757,3	67.406,1	8.648,8	14,72%
	720		ផលនៃការជួលដីធ្លី	47.352,8	34.667,4	-12.685,4	-26,79%
		7201	សម្បទានទេសាទ	9.680,0	8.300,0	-1.380,0	-14,26%
		7202	សម្បទានព្រៃឈើ	33 000,0	20.000,0	-13.000,0	-39,39%
		7204	សម្បទានរ៉ែ	2.420,0	1.938,6	-481,4	-19,89%
		7205	ការជួលដីទំនេរ	2 252,8	4.428,8	2 176,0	96,59%
	721		ផលទុនពីសហគ្រាសសាធារណៈ	11.404,5	32.738,7	21.334,2	187,07%
		7212	ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ	11.403,0	32.738,0	21.335,0	187,10%
		7213	ការបង់ប្រាក់រំលស់	1,5	0,7	-0,8	-53,33%
73			ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា	457.881,7	403.019,8	-54.861,9	-11,98%
	730		សហគ្រាសសាធារណៈ រដ្ឋបាល និង សេវាដំណើរការ (រកចំណេញ)	276.993,9	230.272,2	-46.721,7	-16,87%
		7301	ផលទុនរបស់អាកាសចរស៊ីវិល	50.000,0	50.020,0	20,0	0,04%
		7303	ផលទុនពីសកម្មភាពទេសចរណ៍	75.036,5	84.262,0	9 225,5	12,29%
		7304	ផលទុននៃសកម្មភាពវប្បធម៌	1.000,0	1 130,0	130,0	13,00%
		7305	ផលទុនពីប្រៃសណីយ៍និងទូរគមនាគមន៍	120.000,0	91.853,0	-28.147,0	-23,46%
		7306	ផលទុនពីវិទ្យុទូរទស្សន៍	1.263,8	1.088,0	-175,8	-13,91%
		7307	ផលទុននៃរដ្ឋាករទឹក	15,0	10,0	-5,0	-33,33%
		7308	ផលទុនផ្សេងៗទៀត	29.678,6	1 919,2	-27.759,4	-93,57%

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ក"

ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ		២០០៧/២០០៦	
				២០០៦	២០០៧	កើន (+) / ថយ (-)	ភាគរយ
73	731		រដ្ឋបាល និង សេវា (មិនរកចំណេញ)	9.996,0	9 816,1	-179,9	-1,80%
		7311	ការលក់សំភារៈបរិក្ខារ ,សំភារៈខូចខាត ,សំភារៈសិក្សា	505,0	325,0	-180,0	-35,64%
		7312	លក់ឯកសារ,លតាប័ត្រ,និងលិខិតបោះពុម្ពផ្សេងៗ	8 925,0	8.883,5	-41,5	-0,46%
		7313	ផលនៃការដឹកជញ្ជូនទំនិញ	15,0	8,9	-6,1	-40,67%
		7315	កំរៃនៃការថែទាំ	551,0	598,7	47,7	8,66%
	732		ផលពីការគ្រប់គ្រងរដ្ឋបាល	125.559,9	134.827,2	9.267,3	7,38%
		7321	អាករស្ពានទូត(ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ)	103.400,0	106 080,0	2.680,0	2,59%
		7323	ផលលើការបង្កើតសហគ្រាស	400,0	540,0	140,0	35,00%
		7324	ផលពីការបង់សិទ្ធប្រឡង	240,0	253,0	13,0	5,42%
		7325	ផលពីការលក់ផ្លាកលេខ	1.650,0	1 747,0	97,0	5,88%
		7326	ចំណូលពីប្រដាប់ត្លឹ	490,0	338,0	-152,0	-31,02%
		7327	សេវាសុរិយោដី និង សេវាសំណង់	2.300,0	3.840,0	1 540,0	66,96%
		7328	ផលពីការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋាន	17.079,9	22.029,2	4.949,3	28,98%
	733		ការជួលទ្រព្យសម្បត្តិអចល័ត	45.331,9	28.104,3	-17.227,6	-38,00%
		7331	ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល	18.575,0	8.320,0	-10.255,0	-55,21%
		7332	ការជួលសហគ្រាសសាធារណៈនៅខេត្តក្រុង (មន្ទីរជំនាញ)	3,5	2,4	-1,1	-31,43%
		7333	ការជួលសំភារៈនិងមធ្យោបាយដឹកជញ្ជូន	5,0	2,5	-2,5	-50,00%
		7334	ការជួលអចលនវត្ថុ (អសង្ហារិម)	26.748,4	19 779,4	-6.969,0	-26,05%
74			**ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម**	28,0	50,0	22,0	78,57%
	741		ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម	28,0	50,0	22,0	78,57%
77			**ផលផ្សេងៗ និង ផលពិសេស**	40.000,0	99.696,6	59.696,6	149,24%
	772		ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ	40.000,0	93 454,6	53.454,6	133,64%
	775		ផលពីការលក់អចលនវត្ថុ (ការលក់ទ្រព្យសម្បត្តិរដ្ឋ)	0,0	6.242,0	6 242,0	!!!
			ខ. សរុបចំណូលជាមូលធន (ក្រ១+ក្រ២)	175.605,0	260.133,0	84.528,0	48,14%
			ក្រុមទី១:ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)	175.605,0	260.133,0	84.528,0	48,14%
			ប្រភេទទី១: ចំណូលពីប្រភពផ្ទាល់	32.000,0	30.000,0	-2.000,0	-6,25%
27			**អចលកម្មហិរញ្ញវត្ថុផ្សេងៗ**	32.000,0	30.000,0	-2.000,0	-6,25%
	271		ការអោយខ្ចី (ការសងវិញនូវមូលធន)	32.000,0	30.000,0	-2.000,0	-6,25%
			ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ	143.605,0	230.133,0	86.528,0	60,25%
13			**ឧបត្ថម្ភធនវិនិយោគ**	66.778,0	86.633,0	19.855,0	29,73%
	131		ឧបត្ថម្ភធនទទួលសំភារៈបរិក្ខារ-ទ្វេភាគី	66.778,0	20.500,0	-46.278,0	-69,30%
		1311	ជប៉ុន	66.778,0	20.500,0	46.278,0	-69,30%
	132		ឧបត្ថម្ភធនទទួលសំភារៈបរិក្ខាពីអង្គការអន្តរជាតិ	0,0	66.133,0	66.133,0	!!!

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ក"

ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ		២០០៧/២០០៦	
				២០០៦	២០០៧	កើន (+) / ថយ (-)	ភាគរយ
13	132	1328	ផ្សេងៗ	0,0	66.133,0	66.133,0	!!!
16			**ការខ្ចី និង ចំណូលប្រហាក់ប្រហែល**	76.827,0	143.500,0	66.673,0	86,78%
	162		ការខ្ចីក្រៅប្រទេស	76.827,0	143.500,0	66.673,0	86,78%
		1621	ពហុភាគី	76.827,0	143.500,0	66.673,0	86,78%
			II. សរុបចំណូលជាមូលធនអនុវត្តក្រៅធនាគារជាតិ	857.800,0	1.110.000,0	252.200,0	29,40%
			ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ	857.800,0	1.110.000,0	252.200,0	29,40%
13			**ឧបត្ថម្ភធនវិនិយោគ**	457.500,0	592.000,0	134.500,0	29,40%
	131		ឧបត្ថម្ភធនទទួលពីភារៈបរិក្ខារ-ទ្វេភាគី	457.500,0	592.000,0	134.500,0	29,40%
		1311	ជប៉ុន	42.000,0	0,0	-42.000,0	-100,00%
		1318	ផ្សេងៗ	415 500,0	592.000,0	176.500,0	42,48%
16			**ការខ្ចី និង ចំណូលប្រហាក់ប្រហែល**	400.300,0	518.000,0	117.700,0	29,40%
	162		ការខ្ចីក្រៅប្រទេស	400 300,0	518.000,0	117 700,0	29,40%
		1621	ពហុភាគី	400.300,0	518.000,0	117.700,0	29,40%

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ខ"

ទំព័រ១/៣

ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា:លានរៀល

ក្រសួង_ស្ថាប័ននានា	សរុបរួមចំណាយ	ចំណាយចរន្ត							ចំណាយមូលធន		
		សរុបចំណាយចរន្ត	ប្រភេទទី ១ មធ្យោបាយសេវា	ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ	ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ	ប្រភេទទី ៤ ចំណាយផ្សេងៗ	ប្រភេទទី ៥ ចំណាយតាមដីកា	ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក	សរុបចំណាយមូលធន	ប្រភេទទី ១ ការចូលទាក់ប្រាក់កម្ចី	ប្រភេទទី ២ អចលកម្ម
សរុបរួមចំណាយ	4.622.305,5	2.837.172,5	1.961.190,7	50.000,0	443.058,7	957,0	50,0	381.916,1	1.785.133,0	100.000,0	1.685.133,0
រដ្ឋបាលកណ្តាល	3.927.519,5	2.142.386,5	1.300.540,7	50.000,0	408.963,7	916,0	50,0	381.916,1	1.785.133,0	100.000,0	1.685.133,0
មន្ទីរជំនាញខេត្ត-ក្រុង	694.786,0	694.786,0	660.650,0		34.095,0	41,0					
ក. វិស័យរដ្ឋបាលទូទៅ	402.756,4	402.756,4	315.409,9		87.005,5	291,0	50,0				
រដ្ឋបាលកណ្តាល	378.425,4	378 425,4	291 081,9		87 002,5	291,0	50,0				
មន្ទីរជំនាញខេត្ត-ក្រុង	24.331,0	24.331,0	24 328,0		3,0						
០១. ព្រះបរមរាជវាំង	41 500,0	41.500,0	21.748,0		19 712 0	40,0					
០២. រដ្ឋសភា	67 000,0	67 000,0	64.276,0		2 724,0						
០៣ ព្រឹទ្ធសភា	23.100,0	23 100,0	21.615,0		1 485,0						
០៤. ក្រុមប្រឹក្សាធម្មនុញ្ញ	3.450,0	3.450,0	3 423,0		25 0	2,0					
០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី	85 000,0	85 000,0	29 300,0		55.600,0	100,0					
០៥.២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	1 870,0	1 870,0	1 870,0								
០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	4 279 0	4 279,0	4 224,0		6.0	49,0					
០៧ ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ	26 500,0	26.500,0	24.639,0		1 861 0						
២. រដ្ឋបាលកណ្តាល	26.500,0	26 500 0	24 639,0		1 861,0						
៥ មន្ទីរជំនាញខេត្ត-ក្រុង											
០៨ ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	7 620,0	7 620,0	7 602,0			18,0					
១ រដ្ឋបាលកណ្តាល	4.690,0	4.690 0	4 672,0			18 0					
៥ មន្ទីរជំនាញខេត្ត-ក្រុង	2.930,0	2.930 0.	2.930,0								
០៩ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	60 100,0	60.100,0	59 519,0		564,0	17,0					
១០ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	44.487,0	44.487,0	39 397 0		5 000,0	40,0	50,0				
១ រដ្ឋបាលកណ្តាល	37.987,0	37 987,0	32 897,0		5 000,0	40,0	50,0				
៥ មន្ទីរជំនាញខេត្ត-ក្រុង	6 500,0	6.500,0	6 500 0								
១៤ ក្រសួងផែនការ	9.500,0	9.500,0	9 487,0		13,0						
១ រដ្ឋបាលកណ្តាល	5.100,0	5 100 0	5.090,0		10 0						
៥. មន្ទីរជំនាញខេត្ត-ក្រុង	4 400,0	4 400,0	4.397,0		3,0						
២៦ ក្រសួងយុត្តិធម៌	18 837,0	18 837,0	18.822,0		9.0	6.0					
១ យុត្តធម៌	4 603,0	4 603,0	4 598,0			5 0					
២ តុលាការកំពូល	1 518,0	1 518 0	1 508,0		9,0	1,0					
៣ សាលាឧទ្ធរណ៍	1 320,0	1 320,0	1 320,0								
៤. ក្រុមប្រឹក្សាអង្គចៅក្រម	895,0	895,0	895,0								
៥. មន្ទីរជំនាញខេត្ត-ក្រុង	10.501,0	10.501,0	10 501,0								
៣០. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត	3.729,4	3 729,4	3.710,9		1,5	17,0					
៣១ អាជ្ញាធរសវនកម្មជាតិ	5.784,0	5.784,0	5.777,0		5,0	2,0					
ខ. វិស័យការពារជាតិ និង សន្តិសុខ	507.330,0	507.330,0	491.938,0		15.392,0						
០៦ ក្រសួងការពារជាតិ	320 500,0	320.500,0	312 700,0		7.800,0						
០៧.១ ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ	186.830,0	186 830,0	179.238,0		7 592,0						
គ. វិស័យសង្គមកិច្ច	1.105.296,0	1.105.296,0	926.127,8		178.887,2	281,0					
រដ្ឋបាលកណ្តាល	513.432,0	513 432,0	358.966,8		154 216 2	249,0					
មន្ទីរជំនាញខេត្ត-ក្រុង	591 864,0	591.864,0	567.161,0		24.671,0	32,0					
១១. ក្រសួងព័ត៌មាន	19.113,0	19.113,0	19.069,0		31,0	13,0					
១. រដ្ឋបាលកណ្តាល	14.613,0	14 613,0	14.569,0		31,0	13,0					
៥. មន្ទីរជំនាញខេត្ត-ក្រុង	4 500,0	4.500,0	4.500,0								
១២. ក្រសួងសុខាភិបាល	336.926,0	336.926,0	198.408,0		138.411,0	107,0					
១. រដ្ឋបាលកណ្តាល	238.576,0	238.576,0	103.929,0		134.561,0	86,0					
៥. មន្ទីរជំនាញខេត្ត-ក្រុង	98 350,0	98.350,0	94.479,0		3.850,0	21,0					

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ខ"

ចំណាយថវិកាចរន្តរបស់រដ្ឋ

ឯកតា:លានរៀល

ក្រសួង_ស្ថាប័ននានា	សរុបរួមចំណាយ	ចំណាយចរន្ត: សរុបចំណាយចរន្ត	ប្រភេទ ១ ប្រាក់បៀវត្សរ៍	ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ	ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ	ប្រភេទទី ៤ ចំណាយផ្សេងៗ	ប្រភេទទី ៥ ចំណាយតាមជីកា	ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក	ចំណាយមូលធន: សរុបចំណាយមូលធន	ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី	ប្រភេទទី ២ អចលកម្ម
១៦. ក្រសួងអប់រំ យុវជន និង កីឡា	546.000,0	546.000,0	532.245,8		13.656,2	98,0					
១ អប់រំ	163.000,0	163.000,0	157 099,8		5.810,2	90,0					
២. ឧត្តមសិក្សា	19.000,0	19.000,0	18.599,0		401,0						
៣. យុវជន និង កីឡា	16.000,0	16.000,0	14 055,0		1 945,0						
៩ មន្ទីរជំនាញខេត្ត-ក្រុងនានា	348.000,0	348.000,0	342.492,0		5.500,0	8,0					
១៨. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	18.900,0	18 900,0	17.614,0		1 276,0	10,0					
១. រដ្ឋបាលកណ្ដាល	12.300,0	12.300,0	11.017,0		1 273,0	10,0					
៩ មន្ទីរជំនាញខេត្ត-ក្រុង	6.600,0	6.600,0	6 597,0		3,0						
១៩ ក្រសួងបរិស្ថាន	12 100,0	12 100,0	11 945,0		140,0	15,0					
១ រដ្ឋបាលកណ្ដាល	8 100 0	8 100,0	7 945,0		140 0	15,0					
៩. មន្ទីរជំនាញខេត្ត-ក្រុង	4 000 0	4 000 0	4.000,0								
២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	119 324,0	119.324,0	102 999,0		16 315,0	10,0					
១. រដ្ឋបាលកណ្ដាល	8 050,0	8 050,0	5.400,0		2 640,0	10 0					
៩ មន្ទីរជំនាញខេត្ត-ក្រុង	111 274,0	111 274,0	97.599,0		13.675,0						
២៣. ក្រសួងធម្មការ និង កិច្ចការសាសនា	7 440,0	7 440,0	7.439,0		1,0						
១. រដ្ឋបាលកណ្ដាល	3.000,0	3 000,0	3.000,0								
៩ មន្ទីរជំនាញខេត្ត-ក្រុង	4 440,0	4 440,0	4 439,0		1,0						
២៤. ក្រសួងកិច្ចការនារី	16 400,0	16 400,0	12.140,0		4 242,0	18,0					
១. រដ្ឋបាលកណ្ដាល	9 000,0	9 000,0	5.985,0		3 000 0	15,0					
៩ មន្ទីរជំនាញខេត្ត-ក្រុង	7 400,0	7 400,0	6.155,0		1 242 0	3,0					
៣២. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ	29 093,0	29 093,0	24.268,0		4 815,0	10,0					
១. រដ្ឋបាលកណ្ដាល	21 793,0	21.793,0	17 368,0		4 415 0	10,0					
៩ មន្ទីរជំនាញខេត្ត-ក្រុង	7 300,0	7 300,0	6.900,0		400 0						
ឃ. វិស័យសេដ្ឋកិច្ច	252.374,0	252.374,0	227 715,0		24.274,0	385,0					
រដ្ឋបាលកណ្ដាល	173 783,0	173 783,0	158.554,0		14 853,0	376,0					
មន្ទីរជំនាញខេត្ត-ក្រុង	78 591,0	78.591,0	69 161,0		9 421,0	9 0					
០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	9 950,0	9.950,0	9.453,0		472,0	25,0					
១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	11.020,0	11 020,0	9.774,0		1.231,0	15,0					
១. រដ្ឋបាលកណ្ដាល	5 100,0	5 100,0	4.789,0		296,0	15,0					
៩. មន្ទីរជំនាញខេត្ត-ក្រុង	5.920,0	5.920,0	4 985,0		935,0						
១៥. ក្រសួងពាណិជ្ជកម្ម	23.596,0	23 596,0	20.570,0		3.019,0	7,0					
១. រដ្ឋបាលកណ្ដាល	19 846,0	19 846,0	16.820,0		3 019 0	7,0					
៩. មន្ទីរជំនាញខេត្ត-ក្រុង	3.750,0	3 750,0	3.750,0								
១៧ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ	59 474,0	59.474,0	45.256,0		14 118,0	100,0					
១. រដ្ឋបាលកណ្ដាល	39 274,0	39 274,0	29.442,0		9.732,0	100,0					
៩ មន្ទីរជំនាញខេត្ត-ក្រុង	20.200,0	20.200,0	15.814,0		4 386,0						
២០. ក្រសួងអភិវឌ្ឍន៍ជនបទ	37.260,0	37 260,0	37 222,0			38,0					
១ រដ្ឋបាលកណ្ដាល	22 960,0	22.960,0	22 925,0			35,0					
៩. មន្ទីរជំនាញខេត្ត-ក្រុង	14.300,0	14 300,0	14.297,0			3,0					
២២. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍	32 520,0	32.520,0	31 705,0		800,0	15,0					
១. រដ្ឋបាលកណ្ដាល	28 900,0	28 900,0	28.085,0		800,0	15,0					
៩. មន្ទីរជំនាញខេត្ត-ក្រុង	3.620,0	3.620,0	3.620,0								

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "ខ"

ទំព័រ៧/៣

ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា:លានរៀល

ក្រសួង_ស្ថាប័ននានា	សរុបរួមចំណាយ	ចំណាយចរន្ត: សរុបចំណាយចរន្ត	ចំណាយចរន្ត: ប្រភេទទី ១ មាធ្យោបាយសេវា	ចំណាយចរន្ត: ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ	ចំណាយចរន្ត: ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ	ចំណាយចរន្ត: ប្រភេទទី ៤ ចំណាយផ្សេងៗ	ចំណាយចរន្ត: ប្រភេទទី ៥ ចំណាយតាមដីកា	ចំណាយចរន្ត: ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក	ចំណាយមូលធន: សរុបចំណាយមូលធន	ចំណាយមូលធន: ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី	ចំណាយមូលធន: ប្រភេទទី ២ អចលកម្ម
២៥. ក្រសួងសាធារណការ និង ដឹកជញ្ជូន	21 130,0	21.130,0	20.984,0		40.0	106,0					
១. រដ្ឋបាលកណ្តាល	9.500,0	9.500,0	9.360,0		40,0	100,0					
២ មន្ទីរជំនាញខេត្ត-ក្រុង	11.630,0	11 630,0	11 624,0			6,0					
២៧. ក្រសួងទេសចរណ៍	19.503,0	19.503,0	19.098,0		400,0	5,0					
១. រដ្ឋបាលកណ្តាល	15.143,0	15.143,0	14.738,0		400,0	5,0					
២. មន្ទីរជំនាញខេត្ត-ក្រុង	4.360,0	4.360,0	4.360,0								
២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	16.085,0	16.085,0	16.074,0			11,0					
១. រដ្ឋបាលកណ្តាល	9.900,0	9.900,0	9.889,0			11,0					
២. មន្ទីរជំនាញខេត្ត-ក្រុង	6.185,0	6 185,0	6.185,0								
២៩. ក្រសួងធនធានទឹក និង ឧតុនិយម	21.836,0	21 836,0	17.579,0		4.194,0	63,0					
១. រដ្ឋបាលកណ្តាល	13.210,0	13.210,0	13.053,0		94,0	63,0					
២. មន្ទីរជំនាញខេត្ត-ក្រុង	8.626,0	8.626,0	4 526,0		4.100,0						
៩៩. ចំណាយមិនទាន់បែងចែក	2.354.549,1	569.416,1		50.000,0	137.500,0			381.916,1	1.785.133,0	100.000,0	1.685.133,0
- បន្ទុកហិរញ្ញវត្ថុ (ជំពូក ៦៦)	50.000,0	50.000,0		50.000,0							
- ប្រាក់ឧបត្ថម្ភខេត្ត ក្រុង (ជំពូក ៦៥)	50 000,0	50.000,0			50 000,0						
- ប្រាក់ឧបត្ថម្ភឃុំ សង្កាត់ (ជំពូក ៦៥)	87 500,0	87.500,0			87 500,0						
- ចំណាយត្រៀមបំរុង (ជំពូក ០៩)	349 916,1	349.916,1						349.916,1			
- ចំណាយផ្សេងៗ (ជំពូក ០៩)	32.000,0	32 000,0						32.000,0			
- ការទូទាត់ប្រាក់កម្ចី (ជំពូក ១៦)	100.000,0								100 000,0	100 000,0	
- កំរាលវិនិយោគ	220 000,0								220.000,0		220.000,0
- បដិភាគ	125.000,0								125 000,0		125.000,0
- វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា	230.133,0								230.133,0		230.133,0
- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	1 110 000,0								1 110 000,0		1.110.000,0

ការគ្រប់គ្រងឆ្នាំ ២០០៧

តារាង "គ១"

ចំណាយមូលធននៃវិភាគទានរបស់រដ្ឋ

ផែនការនៃកម្មវិធី

ឯកតា:ពាន់ដុល្លារអាមេរិក

លេខគំរោង	ឈ្មោះគំរោង	តំលៃគំរោង	ប៉ាន់ស្មាន ២០០៦	កម្រិតទុនវិនិយោគចែកតាមឆ្នាំ			
				២០០៧	២០០៨	២០០៩	សរុប ៣ ឆ្នាំ
ក្រសួងសុខាភិបាល							
78	ពង្រឹងសេវាសុខាភិបាលមូលដ្ឋាន	508.821	13.000	30 000	35 000	40.000	105.000
79	សុខភាពស្ត្រី និងកុមារ	57 074	3.168	2.090	2.090	2.090	6.270
82	កម្មវិធីប្រយុទ្ធនឹងជម្ងឺរបេង	105.000	2.000	5 393	6.000	6.000	17.393
83	ការប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់គ្រុនឈាម	47 901	2.218	5.650	6 000	6.000	17.650
84	កែទម្រង់ការចែកចាយឱសថស្ថាន និងសំភារៈបរិក្ខារពេទ្យ	366 915	4.500	20.000	21 000	20 000	61.000
86	កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងកាមរោគ	58.811	4.662	8.181	9.859	10 000	28 040
87	ការស្តារមន្ទីរពេទ្យជាតិ	143 181	5.155	6.787	11 324	11 300	29.411
92	ការថែរក្សាភ្នែក ច្រមុះ បំពង់ក	8.155	500	500	500	500	1.500
426	ត្រួតពិនិត្យគ្រប់គ្រងចំណីអាហារ និងថ្នាំសង្កូវ	8.699	656	600	259	700	1 559
701	អភិវឌ្ឍឱសថបុរាណ	4.935	600	700	600	600	1 900
886	លើកកម្ពស់សេវាត្រចៀក ច្រមុះ បំពង់ក ភ្នែក ធ្មេញ	4 149	318	364	418	418	1.200
962	គំរោងគ្រប់គ្រងជម្ងឺកុមារ (IMCI)	5.567	500	500	500	500	1 500
1094	ការត្រួតពិនិត្យគ្រុនផ្តាសាយនៅកម្ពុជា	146	27	-	-		-
1095	គំរោងការពារជម្ងឺ HIV/AIDS	476	119	-	-		-
1096	ការផ្តល់សុខភាពបឋមនៅខេត្តកំពង់ចាម	5.213	1 303	1.303	1 086		2.389
1097	ការផ្តល់សេវាកម្មសុខភាពបឋមនៅខេត្តសៀមរាប និងឧត្តរមានជ័យ	5.725	1 431	1 431	596		2.028
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា:លានរៀល

ជំពូក	ការរាយមុខ	ឥណទានដើមឆ្នាំ	ចលនាឥណទាន		ស្ថានភាពឥណទានថ្មី
			កើន	ថយ	
	ការផ្ទេរចេញ			347.500	
	៥៥- ចំណាយមិនទាន់បែងចែក			347.500	
៦៦	បន្ទុកហិរញ្ញវត្ថុ (ការប្រាក់)	50.000	-	50.000	0
៦៥	ឧបត្ថម្ភធន និង ជំនួយសង្គម (ខេត្ត-ក្រុង/ឃុំ-សង្កាត់)	137.500	-	137.500	0
០៥	ចំណាយមិនបានគ្រោងទុក	381.916,1	-	110.000	271.916,1
១៦	ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល	100.000	-	50.000	50.000
	ការផ្ទេរចូល		347.500		
	១០- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ		346.500		
៦១	សេវាខាងក្រៅ (ថៃទាំផ្លូវថ្នល់)	926	84.000	-	84.926
៦៦	បន្ទុកហិរញ្ញវត្ថុ (ការប្រាក់)	0	50.000	-	50.000
៦៥	ឧបត្ថម្ភធន និង ជំនួយសង្គម (ខេត្ត-ក្រុង/ឃុំ-សង្កាត់)	5.000	137.500	-	142.500
៦៣	ពន្ធ និង អាករ	40	25.000	-	25.040
១៦	ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល	0	50.000	-	50.000
	១៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា		1.000		
៦៥	ឧបត្ថម្ភធន និង ជំនួយសង្គម	2.640	1.000	-	3.640

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៦ អនក្រ-បក

អនុក្រឹត្យ
ស្តីពីការបន្ថែមប្រាក់ឧបត្ថម្ភជូនកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងគ្រូបង្រៀន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និង យុទ្ធជនពិការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយបន្ថែមប្រាក់បៀវត្ស ១៥ ភាគរយ សំរាប់ឆ្នាំ ២០០៧ លើបៀវត្សសុទ្ធសាធ ជូនកងយោធពលខេមរៈភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និង យុទ្ធជនពិការ ។

មាត្រា២ : ប្រាក់បន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ ចាប់អនុវត្តពី ខែ មករា ឆ្នាំ ២០០៧ តទៅ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការដែលជាប្រធានក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤ . អនក្រ . តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំងលោកស្រី **ហៃ សុន្ធារិទ្ធ** អតីតអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហព័ន្ធអាល្លឺម៉ង់ ជាប្រធាននាយកដ្ឋានអង្គការប្រាង់កូហ្វូនី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-ឧត្តមសេនីយ៍ឯក **ម៉ែន សាំ** អត្តលេខ ០០០២៣២ ជា អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឧត្តមសេនីយ៍ឯក **មាស សំអុល** អត្តលេខ ០០០២១១ ជា អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឧត្តមសេនីយ៍ទោ **សួន សំណាង** អត្តលេខ ០០០២០៦ ជា អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និងជា នាយក នាយកដ្ឋាននយោបាយផែនការ

៤-ឧត្តមសេនីយ៍ទោ **ខៅ សាខន** អត្តលេខ ០០១២០៣ ជា អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

៥-ឧត្តមសេនីយ៍ត្រី **ជា សន្ធា** អត្តលេខ ០០០០៨៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៦-ឧត្តមសេនីយ៍ត្រី **ទឹម សិន្ធា** អត្តលេខ ០០០៦៣១ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៧-ឧត្តមសេនីយ៍ត្រី **ង៉ែន សាម៉ិន** អត្តលេខ ០០០៦៣២ ជា នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ

៨-វរសេនីយ៍ឯក **ម៉ុន ចន** អត្តលេខ ០០៤២៣៦ ជា នាយក នាយកដ្ឋានការពារគីមីសាស្ត្រ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

៚ ✳ ៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពី ការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ទោ	**សុខុន មញ្ញរិទ្ធ**	អត្តលេខ ០០៤០២៦	នាយសេនាធិការរង	កងពលតូចលេខ៧០
២-វរសេនីយ៍ទោ	**ខៀវ ទាន់សារិទ្ធ**	អត្តលេខ ០០១៣៤៦	នាយសេនាធិការរង	កងពលតូចលេខ៧០
៣-វរសេនីយ៍ទោ	**ហួត ឈាងអន**	អត្តលេខ ២៣១៨៩២	នាយសេនាធិការរង	កងពលតូចលេខ៧០
៤-វរសេនីយ៍ទោ	**ឡុង ម៉េង**	អត្តលេខ ០១០៩៦៤	នាយសេនាធិការរង	កងពលតូចលេខ៧០
៥-វរសេនីយ៍ទោ	**ខែម ម៉ូ**	អត្តលេខ ២៣៤០១៦	នាយសេនាធិការរង	កងពលតូចលេខ៧០

៦-វរសេនីយ៍ទោ	ឡៅ	ឌុចហាំង	អត្តលេខ ០៨៤៥៨៧	នាយសេនាធិការរង កងពលតូចលេខ៧០
៧-វរសេនីយ៍ទោ	សុខ	ម៉េង	អត្តលេខ ០១២៣៨៦	នាយសេនាធិការរង កងពលតូចលេខ៧០
៨-វរសេនីយ៍ទោ	សេង	សាន្ត	អត្តលេខ ០១៦៣៣៤	នាយសេនាធិការរង កងពលតូចលេខ៧០
៩-វរសេនីយ៍ទោ	មឹក	សុផាណារេត	អត្តលេខ ០០៣៣៨៦	ជំនួយការនាយករង ខុទ្ទកាល័យ សម្តេចប្រធាន ព្រឹទ្ធសភា កងពលតូចលេខ៧០

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៣...អនក្រ.ទស

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧៣

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន CIRCEL K SUNKUS Co.ltd ដែលបានឧបត្ថម្ភថវិកាតាមរយៈអង្គការ JHP មានទឹកប្រាក់ចំនួន ៧៣.៤៨៤ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង ០២ជាន់ មាន០៨បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹម និងប្រព័ន្ធអគ្គិសនីគ្រប់គ្រាន់ នៅអនុវិទ្យាល័យបឹងកុក ក្នុងស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានឧបត្ថម្ភថវិកា ជួយសាងសង់អគារសិក្សា នៅសាលាបឋមសិក្សា ឈើតុំ ក្នុងភូមិកាប់ស់ ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិសាត់ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម FUMIAKI TAKAHASHI ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា, បានឧបត្ថម្ភថវិកា ចំនួន ៣១.៩១៦ ដុល្លារ សំរាប់សាងសង់អគារ ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង និងអណ្តូងទឹក ០១ ។

២-លោក WATANABE MIKI អគ្គនាយកអង្គការ School Aid Japan បានឧបត្ថម្ភថវិកា ចំនួន ២៩.៦២៥ ដុល្លារ សំរាប់សាងសង់អគារ ០១ខ្នង មាន០៥បន្ទប់ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៥...អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តឧត្តរមានជ័យ

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ខេត្តឧត្តរមានជ័យ ចំនួន ១២រូប ដែលមានស្នាដៃល្អក្នុងការរួមចំណែកដល់កិច្ចស្ថាបនា និងអភិវឌ្ឍន៍ខេត្ត ដូចមានរាយនាមខាងក្រោម :-

១-លោក	ទៀវ ម៉ូរ	ប្រធានមន្ទីរបរិស្ថានខេត្ត
២-លោក	ចាន់ ចន្ថារ៉ា	ប្រធានមន្ទីរវប្បធម៌-វិចិត្រសិល្បៈ ខេត្ត
៣-លោកស្រី	ឯក សុវណ្ណនារៈ	អនុប្រធានមន្ទីរកិច្ចការនារី ខេត្ត
៤-លោក	ឡុង វណ្ណធន	ប្រធានមន្ទីរទេសចរណ៍ ខេត្ត
៥-លោក	លឹម ហាក់	ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត
៦-លោក	ឈន់ ញ៉ាញ់	អនុប្រធានមន្ទីរផែនការ ខេត្ត
៧-លោក	ឌិម ឈើឈី	អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត
៨-លោក	ហាំង ម៉េង	នាយរងខុទ្ទកាល័យសាលាខេត្តឧត្តរមានជ័យ
៩-លោក	ចាប ផាត	អភិបាលរងស្រុកបន្ទាយអំពិល
១០-លោក	នេត្រ ដារ៉ា	នាយរងខុទ្ទកាល័យសាលាខេត្តឧត្តរមានជ័យ
១១-លោក	ស្វោម ខ្មៅ	នាយរងខុទ្ទកាល័យសាលាខេត្តឧត្តរមានជ័យ
១២-លោក	គោរ វុទ្ធី	ប្រធានទីប្រឹក្សា PLG នៃកម្មវិធីសិលាខេត្ត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ....៤០....អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តឧត្តរមានជ័យ

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំមន្ត្រីរាជការ ខេត្តឧត្តរមាន-ជ័យ ចំនួន ២៣រូប ដែលមានស្នាដៃល្អក្នុងការរួមចំណែកដល់កិច្ចស្ថាបនា និងអភិវឌ្ឍន៍ខេត្ត ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-ឯកឧត្តម	ភ្នៅ	ស្ទួ	អភិបាលរងខេត្ត
២-លោក	យ៉ែម	ចិន	អភិបាលរងខេត្ត
៣-លោក	អ៊ុំ	ចិន	អភិបាលរងខេត្ត
៤-លោក	ជុំ	ជាតិ	អភិបាលរងខេត្ត
៥-លោក	សាន	វណ្ណា	អភិបាលរងខេត្ត

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោក	ថុន	ណារុយ	នាយខុទ្ទកាល័យ
២-លោក	យ៉ែម	ដាន់ណា	អភិបាលស្រុកអន្លង់វែង
៣-លោក	មុី	សាខន	អភិបាលស្រុកសំរោង
៤-លោក	គឹម	នុន	អភិបាលស្រុកចុងកាល់
៥-លោក	វណ្ណ	កុសល	អភិបាលស្រុកត្រពាំងប្រាសាទ
៦-លោក	ខាម	ឃួត	អភិបាលស្រុកបន្ទាយអំពិល
៧-លោក	ឡៅ	ឆន	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត
៨-លោក	អ៊ុំ	ប៊ុរ៉ាត់	ប្រធានមន្ទីរអប់រំ យុវជននិងកីឡា ខេត្ត

៩-លោក	ស៊ី	ប្រាសិទ្ធិ	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត
១០-លោក	អ៊ុក	គឹមសឿន	ប្រធានមន្ទីរសុខាភិបាល ខេត្ត
១១-លោក	ម៉េង	ម៉ៅអ៊ាន់ឌី	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត
១២-លោក	ឃិន	ញ៉ាណ	ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្ត
១៣-លោក	សូរ	គឹមតន់	ប្រធានមន្ទីរផែនការ ខេត្ត
១៤-លោក	យឹម	ម៉ុនថន	ប្រធានមន្ទីរព័ត៌មាន ខេត្ត
១៥-លោក	ហែម	ហ៊ីម	ប្រធានមន្ទីរ អធិការកិច្ច ទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា
១៦-លោក	ឃួន	សៃ	ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត
១៧-លោក	នួន	សឺន	ប្រធានមន្ទីររតនាគារ ខេត្ត
១៨-លោក	ដុំ	សំនិត	ប្រធានមន្ទីរពន្ធដារ ខេត្ត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..០២..សស.សរ

សេចក្តីសំរេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ១២ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ចាប់ពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧ នៅទីក្រុងសេប៊ូ សាធារណរដ្ឋហ្វីលីពីន រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍ មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់ រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០១២ សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦

សារាចរ

ស្ដីពី

ការណែនាំលើការអនុវត្តន៍ថវិកាឆ្នាំ ២០០៧

I. សេចក្ដីផ្ដើម

១. ច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ។ ដោយផ្អែកលើច្បាប់នេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការដាក់អោយអនុវត្ត ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ លេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ និង អនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ។ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ និង អនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញ ប្រកាសលេខ ១៤០២ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យរដ្ឋ ប្រកាសលេខ ១៤០៣ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការដាក់អោយអនុវត្ត ប្លង់គណនេយ្យទូទៅនៃគណនេយ្យថវិកាខេត្ត-ក្រុង ប្រកាសលេខ ១៤០៤ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅនៃគណនេយ្យថវិកាស្រុក-ខណ្ឌ ប្រកាសលេខ ១៤០៥ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការរៀបចំ និង កិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល ប្រកាសលេខ ១៤១៥ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្ដាល ក្នុងការពិនិត្យសំរេចចុះទិដ្ឋាការលើលិខិតធានាចំណាយ និង លើអាណត្តិបើកប្រាក់ ប្រកាសលេខ ១៤១៦ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការប្រគល់ ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ប្រកាសលេខ ១៤១៧ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពី ការបែងចែកចំណាយឥណទានថវិកាផ្ទៃក្នុងជំពូកតាម គណនី និង អនុគណនី

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងរជ្ជទេយ្យចំណូល សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន និង សារាចរណែនាំលេខ ០១៥ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈ ។ ដើម្បីឱ្យការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ មានដំណើរការប្រកបដោយលទ្ធផលល្អ និង មានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តន៍ថវិការដ្ឋ ឆ្នាំ ២០០៧ ដែលមានតាមលំដាប់លំដោយដូចតទៅ ។

២- ថវិកាឆ្នាំ ២០០៧ ត្រូវបានរៀបចំឡើងដោយផ្អែកលើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសដើម្បីបំរើអោយការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តន៍យុទ្ធសាស្ត្រទាំង ៤ គឺ (១) ការជំរុញការអភិវឌ្ឍន៍វិស័យកសិកម្ម និង កសិឧស្សាហកម្ម (២) ការជំរុញការអភិវឌ្ឍន៍វិស័យឯកជន និង បង្កើនការងារ (៣) ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធធារាសាស្ត្រ និង (៤) ការបន្តជំរុញការកសាងសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍន៍ធនធានមនុស្ស ព្រមទាំងបន្តជំរុញអោយកាន់តែខ្លាំងក្លាថែមទៀតលើការដ្ឋានទាំង ៤ នៃ អភិបាលកិច្ចល្អគឺ (១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២) កំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ (៣) កំណែទំរង់រដ្ឋបាលសាធារណៈ និង (៤) កំណែទំរង់កងកំលាំងប្រដាប់អាវុធ ។ ទន្ទឹមនឹងនេះ ដើម្បីបន្តបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ជាពិសេស បង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលនឹងបន្តជំរុញ (១) ការអនុវត្តន៍កំណែ ទំរង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន (២) ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ សម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន (៣) ការកសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង បទបញ្ជា ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និង អភិបាលកិច្ចល្អ (៤) ការអនុវត្តកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ និង ការអភិវឌ្ឍន៍មូលដ្ឋាន និង (៥) ការបន្តជំរុញការអនុវត្តន៍ ផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមនៅវិស័យអប់រំ និង វិស័យសុខាភិបាល និង ការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមសំរាប់វិស័យកសិកម្ម និង ធនធានទឹក ដែលជាវិស័យអាទិភាពនៃគោលនយោបាយចំណាយសាធារណៈរបស់រាជរដ្ឋាភិបាល និង ជាមុខព្រួញចំណាយដ៏សំខាន់ដែលមានឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

II. លំនាំទិសដៅ និង វិធានការក្នុងការអនុវត្តថវិកាឆ្នាំ ២០០៧

ក- ការអនុវត្តការប្រមូលចំណូលថវិកា

៣. ដើម្បីអោយការអនុវត្តច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សំរេចបានជោគជ័យ ជាពិសេស ដើម្បីអោយការអនុវត្តថវិកាសំរេចបានតាមការគ្រោងទុក ជាក់ស្តែងគឺដើម្បីអោយការប្រមូលចំណូលក្នុងស្រុក សំរេចបានតាមគោលដៅ ៣ ៤០០ ៥៧៣ លានរៀល គឺស្មើនឹង ១០,៩២% នៃផសស រាជរដ្ឋាភិបាលនឹងជំរុញ ការបង្កើនការប្រមូលចំណូលចរន្តអោយបាន ៣ ៣៧០ ៥៧៣ លានរៀល បើធៀបទៅនឹងចំណូលចរន្តនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ គឺនឹងត្រូវកើនឡើង ១៧,៣១% ដែលក្នុងនោះចំណូលសារពើពន្ធនឹងត្រូវ កើន ២០,៩៦% (ចំណូលគយ និង រដ្ឋាករនឹងត្រូវកើន ៩,៩៣% និង ចំណូលពន្ធដារនឹងត្រូវកើន ៥០,៤៥%) និង ចំណូលមិនមែនសារពើពន្ធនឹងត្រូវកើន ២,៧៥% ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានចេញបទបញ្ញត្តិស្តីពីការ គ្រប់គ្រងចំណូលមិនមែនសារពើពន្ធលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ដែលរួមមាន វិធានការ ប្រមូលចំណូល វិធានការគ្រប់គ្រងចំណុល និង វិធានការលើកទឹកចិត្ត ពិន័យ និង ទណ្ឌកម្ម ក្នុងគោលដៅ ពង្រឹងការប្រមូល និង គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

៤- ថវិកាឆ្នាំ ២០០៧ បានឆ្លុះបញ្ចាំងពីកំណើននៃចំណូលធៀបនឹងចំណូលថវិកាឆ្នាំ ២០០៦ ជាពិសេស ការបង្កើនចំណូលក្នុងស្រុកអោយដល់ ៣ ៤០០ ៥៧៣ លានរៀល គឺស្មើនឹង ១០,៩២% នៃផសស (ចំណូលក្នុង ស្រុកដែលជាថវិការដ្ឋមាន ៣ ២៨២ ១៧៣ លានរៀល គឺស្មើនឹង ១០,៥៤% នៃផសស និង ចំណូលថវិកា ខេត្ត-ក្រុងមាន ១១៨ ៤០០ លានរៀល) ដែលនឹងមានកំណើនស្មើនឹង ១៧,១៧% (ចំណូលថវិការដ្ឋកើន ១៦,៨២% និង ចំណូលថវិកាខេត្ត-ក្រុងកើន ២៧,៨៦%) ធៀបនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៦ ។ ការបង្កើន និង ពង្រឹងការកៀរគរចំណូលគឺជាយុទ្ធសាស្ត្រស្នូលនៃគោលនយោបាយថវិកាឆ្នាំ ២០០៧ ជាពិសេស ការផ្តោតជាសំខាន់ទៅលើការពង្រឹងរដ្ឋបាលពន្ធដារ និង រដ្ឋបាលគយ និង រដ្ឋាករ ក្នុងគោលដៅសំរេចឱ្យបាននូវ ចំណូលសារពើពន្ធ ២ ៧៧៨ ៤៥៤ លានរៀល គឺស្មើនឹង ៨,៩២% នៃផសស (ចំណូលសារពើពន្ធជាថវិការដ្ឋមាន ៨,៦១% និង ចំណូលសារពើពន្ធជាថវិកាខេត្ត-ក្រុងមាន ០,៣១%) ដែលមានកំណើនស្មើនឹង ១៦% ធៀបនឹង លទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៦ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពង្រឹងការអនុវត្តឱ្យមាន ប្រសិទ្ធភាពនូវច្បាប់ស្តីពីសារពើពន្ធ ពង្រឹង និង ពង្រីកសមត្ថភាពស្ថាប័ន ពង្រីកមូលដ្ឋានយកពន្ធ ព្រមទាំង ទប់ស្កាត់អំពើគេចពន្ធគ្រប់បែបយ៉ាង ។ ម្យ៉ាងទៀត ចំណូលមិនមែនសារពើពន្ធនឹងសំរេចអោយបាន ៥៩២ ១១៩ លានរៀល គឺស្មើនឹង ១,៩០% នៃផសស (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋមាន ៥៧០ ១៧៣ លានរៀល គឺស្មើនឹង ១,៨៣% នៃផសស) បើធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៦ គឺមានការកើនឡើង ២,៧៥% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋកើនឡើង ២,៤៣% និង ចំណូលមិនមែនសារពើពន្ធដែលជាថវិកា ខេត្ត-ក្រុងកើនឡើង ១១,៩៧%) តែបើធៀបនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៦ នឹងកើនឡើង

២៤,៦៦% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋនឹងកើនឡើង ២៥,២០% និង ចំណូលមិនមែនសារពើពន្ធដែលជាថវិកាខេត្ត- ក្រុងកើនឡើង ១១,៩៧%) ។

៥- ដើម្បីសំរេចបានតាមគោលដៅខាងលើ នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ ត្រូវរៀបចំកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលំអិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ នាយកដ្ឋានពន្ធដារមានកាតព្វកិច្ចប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យបានជាមធ្យមចំនួន ៦៥,៨៣ ពាន់លានរៀលក្នុងមួយខែ ។ ចំណែកទីចាត់ការគយ និង រដ្ឋាករមានកាតព្វកិច្ចប្រមូលចំណូលពន្ធអាករឱ្យបានជាមធ្យមចំនួនប្រមាណ ១៤៧,៥៨ ពាន់លានរៀលក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកំរិតខ្ពស់ ឬទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលំអិតហើយប្រគល់ឱ្យសាខាទីស្នាក់ការ និង មន្ត្រីម្នាក់ៗដើម្បីទទួលខុសត្រូវដោយផ្ទាល់ទៅតាមកាតព្វកិច្ចដែលខ្លួនត្រូវបំពេញរៀងៗ ខ្លួន ។

៦- ដើម្បីសំរេចបាននូវការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ ២០០៧ ចំនួន ៥៩២,១១៩ ពាន់លានរៀល ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុងត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលំអិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និង សង្វាក់នៃការប្រមូលចំណូលកន្លងមក ។ ក្រសួង-ស្ថាប័នត្រូវប្រគល់ការអនុវត្តន៍កម្មវិធីនេះ ទៅឱ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និងនៅខេត្ត-ក្រុងអោយទទួលខុសត្រូវដោយផ្ទាល់ចំពោះការប្រមូលចំណូលទាំងនោះ ។ អង្គភាពប្រមូលចំណូល ត្រូវធ្វើការតាមដាន និង ជំរុញជាប្រចាំនូវការអនុវត្តន៍កម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និង វិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ជាពិសេស ត្រូវគោរព និង អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ។

៧- ទន្ទឹមនឹងនេះ ដើម្បីអោយការអនុវត្តន៍កម្មវិធីប្រមូលចំណូលប្រចាំត្រីមាសសំរេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗ ត្រូវធ្វើការតាមដាន និង ត្រួតពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និង ប្រចាំត្រីមាស) លើលទ្ធផលដែលសំរេចបាន ដើម្បីវិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ។ ក្រៅពីការធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ និង ប្រចាំខែ អង្គភាពនីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តន៍ចំណូលរបស់ខ្លួនសំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង មានវិធានការតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសំរេចបាន និង ចំណុចខ្វះខាតដែលបានកត់សំគាល់ព្រមទាំងលើកឡើងនូវសំណូមពរ និង អនុសាសន៍ដើម្បីកែលំអ និង បង្កើនប្រសិទ្ធភាពប្រមូលចំណូល ។

៨- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

ទីមួយ- ការពង្រឹងសមត្ថភាពរួមសំរាប់គ្រប់គ្រង និង ប្រមូលចំណូល:

- បន្តជំរុញការកសាង និង រៀបចំដាក់អោយអនុវត្តនូវបង្កាន់ដៃជាតិមួយដែលឯកភាព សំរាប់ប្រើប្រាស់ក្នុងការចុះបញ្ជី និង តាមដានការគ្រប់គ្រងលើការប្រមូលចំណូលគ្រប់ប្រភេទ ។
- បន្តជំរុញការរៀបចំយន្តការ និង ណែនាំអោយអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ជា និង វិន័យលើការប្រមូលចំណូលថវិការដ្ឋគ្រប់ប្រភេទ ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។
- បន្តជំរុញការកសាងបណ្តុះបណ្តាលនានាដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការកសាងគោលនយោបាយ និង យន្តការគ្រប់គ្រងកម្មវិធីសមាហរណកម្មពេញលេញនៃការកៀរគរធនធានថវិកា ជាពិសេស ការបង្កើនសមត្ថភាពវិភាគព្យាករណ៍ និង ស្វែងរកប្រភពចំណូលថ្មី ។
- បន្តជំរុញការបង្កើតក្របខ័ណ្ឌសំរាប់កៀរគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់ រដ្ឋបាល និង ផ្តល់ការណែនាំដល់ការកសាងវិធានការ សំដៅបង្កើនធនធានទៅតាមខេត្ត- ក្រុង និង ឃុំ- សង្កាត់ ។
- បន្តជំរុញការកសាងបណ្តុះបណ្តាលសំរាប់រយៈពេលមធ្យម និង វែង ពាក់ព័ន្ធនឹងកម្មវិធីសមាហរណកម្មនៃការកៀរគរធនធានថវិកា សំដៅបំពីនិស្សិការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
- បន្តជំរុញការកសាងបណ្តុះបណ្តាលក្នុងការធ្វើសមាហរណកម្មការកៀរគរធនធានថវិកា ដើម្បីកំណត់បញ្ចូលទៅក្នុងដំណើរការកសាងថវិកាជាតិ និង ដំណើរការត្រួតពិនិត្យឡើងវិញនៃការអនុវត្តន៍ថវិកាជាតិ ។
- បន្តជំរុញការកំណត់ឱ្យបានច្បាស់លាស់នូវបំណុលពន្ធ និង បំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និង តឹងទារឱ្យមានប្រសិទ្ធភាព ។
- បន្តជំរុញពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ទាំងសវនកម្មផ្ទៃក្រៅ និង ការងារអធិការកិច្ច ទាំងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ទាំងអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលើការគ្រប់គ្រងថវិកាជាតិជាពិសេសលើការប្រមូលចំណូល ។

ទីពីរ- ការកៀរគរចំណូលផ្នែកគយ និង រដ្ឋាករ:

- បន្តជំរុញការកសាង និង ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិខាងផ្នែកគយជាមួយប្រទេសដៃគូរពាណិជ្ជកម្មអន្តរជាតិ ជាពិសេសបណ្តាប្រទេសជាប់ព្រំដែនដើម្បីទប់ស្កាត់អំពើល្មើសគេចពន្ធ តាមរយៈការផ្តល់ព័ត៌មាន- និង ការបញ្ជាក់ទៅវិញទៅមកពាក់ព័ន្ធនឹងការនាំចេញ- នាំចូលមុខទំនិញដែលមានវេទយិតភាពខ្ពស់លើចំណូល ។
- បន្តជំរុញការអនុវត្តន៍វិធានការទប់ស្កាត់ការជ្រាបចូលទីផ្សារ នៃទំនិញដែលនាំចូលតាមរបបអនុគ្រោះនានា ដោយដាក់អោយដំណើរការនូវប្រព័ន្ធជំរះបញ្ជីច្បាស់លាស់ ។

- បន្តពង្រឹងយន្តការត្រួតពិនិត្យទំនិញមុនពេលផ្ទុកបន្ថែមទៀត ដើម្បីកាត់បន្ថយជាអតិបរមានូវទំនិញនាំចូលដែលមិនឆ្លងការត្រួតពិនិត្យទំនិញមុនពេលផ្ទុកអោយបានត្រឹមត្រូវ ។

- បន្តជំរុញការអនុវត្តន៍យន្តការឆ្លងកាត់ជាតិ ដើម្បីយកទំនិញសំខាន់ៗមួយចំនួន មកបំពេញបែបបទនៅជិតតំបន់ប្រើប្រាស់ ជៀសវាងការចំណាយមិនចាំបាច់នានានៅតាមច្រក និង តាមដងផ្លូវ ងាយស្រួលដល់ផ្នែកផ្សេងទៀតជួយឃ្លាំមើល និង សង្កេតការណ៍ ។

- បន្តកែសំរួលនិតិវិធីត្រួតពិនិត្យរបស់គយអោយកាន់តែមានប្រសិទ្ធភាព លើទំនិញនាំចូលនាពេលបំពេញបែបបទបញ្ចេញទំនិញ ពេលដឹកជញ្ជូន ពេលសន្និធិ និង ពេលចរាចរចែកចាយ ។

- បន្តជំរុញការរៀបចំ និង អនុវត្តការធ្វើសវនកម្មក្រោយការយកទំនិញចេញពីគយ ដើម្បីធានាភាពត្រឹមត្រូវនៃប្រតិបត្តិការគយ ។

- បន្តជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស រួមទាំងការជ្រើសរើស និង ហ្វឹកហ្វឺនមន្ត្រី និង ភ្នាក់ងារគយ និង រដ្ឋាករ ។

- បន្តអនុវត្តយុទ្ធសាស្ត្រចាប់បង្ក្រាប និង គោលការណ៍គ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយការគេចពន្ធ និងបណ្តាសកម្មភាពខុសច្បាប់ផ្សេងៗនៅតាមព្រំដែន ។

- បន្តជំរុញការពង្រឹងក្របខ័ណ្ឌគតិយុត្ត ដោយផ្អែកលើច្បាប់គយថ្មីដោយការអនុវត្តន៍យ៉ាងហ្មឺងម៉ាត់ ក្នុងនោះរួមមានទាំងការកសាងគោលនយោបាយគយ និង រដ្ឋាករ និង ការចងក្រងសេចក្តីណែនាំអនុវត្ត នីតិវិធីគយ ។

- បន្តជំរុញការអនុវត្តន៍កម្មវិធីគ្រប់ជ្រុងជ្រោយរបស់គយក្នុងការវិភាគលើចំណូល និង ការផ្តល់តួរលេខចំណូល និង ស្ថិតិពាណិជ្ជកម្មប្រកបដោយបច្ចុប្បន្នភាព និង សុក្រឹតភាព ។

- បន្តជំរុញការអនុវត្តន៍គំរោងបំពាក់បច្ចេកវិទ្យាពត៌មានដល់ទីចាត់ការគយ និង រដ្ឋាករ ហើយរៀបចំវិធានការរយៈពេលខ្លីសំរាប់ការអនុវត្តន៍កម្មវិធីស្វ័យប្រវត្តកម្មគយ រួមទាំងការរៀបចំបង្កើតមូលដ្ឋាន ច្បាប់ និង នីតិវិធីដែលមានការពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និង ការរៀបចំគំរោងផង ។

- បន្តជំរុញការកំណត់ និង អនុវត្តវិធានការពង្រឹងស្ថាប័នគយ រួមទាំងការកែលំអរចនាសម្ព័ន្ធនៃការផ្តល់កំរៃ និង ការលើកទឹកចិត្តដល់មន្ត្រីគយ និង ការអភិវឌ្ឍន៍កម្មវិធីអភិបាលកិច្ចល្អផង ។

<u>ទីបី-ការកៀរគរចំណូលពន្ធដារៈ</u>

- រៀបចំ និង ដាក់អោយអនុវត្តការវាយតំលៃ សំរាប់គិតអាករពិសេសលើផលិតផលក្នុងស្រុកតាមថ្លៃលក់ចេញពីរោងចក្រគត់ត្រាក្នុងវិក័យប័ត្រ (ex-factory price) ។

- រៀបចំ និង ដាក់អោយអនុវត្តនូវការកែប្រែមូលដ្ឋានសំរាប់ការគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់តាមរយៈការធ្វើវិសោធនកម្មមាត្រា ៣០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

- រៀបចំ និង ដាក់អោយអនុវត្តនូវពន្ធលើប្រាក់ចំណេញមូលធន (capital gain) តាមរយៈការធ្វើវិសោធនកម្មមាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

- បន្តពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេស អាករលើតំលៃបន្ថែម និង យន្តការបង្វិលសង អាករលើតំលៃបន្ថែម ។

- បន្តកែលំអការវិភាគ និង ការព្យាករណ៍លើចំណូលពន្ធដារក្នុងទិសដៅបង្កើតបណ្តាជំរើសគោលនយោបាយថ្មីៗ ដើម្បីបង្កើនចំណូលពន្ធ ។

- បន្តជំរុញការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងកំរិតអតិបរមា ដើម្បីសំរួលដល់ការបង់ពន្ធជាពិសេស ចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម ។

- បន្តពង្រឹងឱ្យបានគ្រប់ជ្រុងជ្រោយនូវសវនកម្មពន្ធពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំនិងមធ្យម ។

- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្តយ៉ាងហ្មឹងម៉ាត់នូវការតឹងទារបំណុលពន្ធដារ ក្នុងនោះរួមមានការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាពត៌មានសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង និង ការធ្វើសវនកម្មពន្ធនៅនឹងកន្លែង ព្រមទាំងការជំរះបញ្ជីអ្នកជាប់ពន្ធផងដែរ ។

- បន្តអនុវត្តវិធានការពង្រឹងនាយកដ្ឋានពន្ធដាររួមទាំងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការជ្រើសរើសមន្ត្រីថ្មីបន្ថែម ការកែលំអសេវាបំរើឱ្យអ្នកជាប់ពន្ធ ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាល ការធ្វើសវនកម្មផ្ទៃក្នុង និង ការបំពាក់នូវទុកសិការៈចាំបាច់ផ្សេងៗ ។ល។

- បង្កើនការផ្ទៀងផ្ទាត់ពត៌មានដើម្បីស្វែងរកផលរបរនៅក្នុងរបបម៉ៅការដែលត្រូវផ្ទេរទៅរបបពិត ។

- ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និង ប្រមូលចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ផ្សេងៗ ដោយសិក្សាពីបទពិសោធន៍អន្តរជាតិពាក់ព័ន្ធនឹងជំរើសដែលអាចបង្កើនចំណូលពីអាជីវកម្មឆ្នោត និង បណ្តាល្បែងភ្នាល់នានា ។

- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការកាស៊ីណូ និង ពង្រឹងការប្រមូលចំណូលពីកាស៊ីណូឱ្យបានកើនឡើងសមស្របនឹងចំណូលជាក់ស្តែងនៃអាជីវកម្មក្នុងវិស័យនេះ ក្នុងនោះរួមមានការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និង មន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូលនេះផងដែរ ។

<u>*ទីបួន-ការពង្រឹងការគ្រប់គ្រង និង ការកៀរគរចំណូលមិនមែនសារពើពន្ធៈ*</u>

- រៀបចំ និង ដាក់អោយអនុវត្តនូវការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាតិលើការប្រកបសេវាកម្មវាយតំលៃ និង ការជួញដូរអចលនវត្ថុ ។

- បន្តចុះសិក្សា និង ស្រាវជ្រាវរាល់បំណុលទាំងអស់ ដើម្បីរៀបចំគោលការណ៍ និង នីតិវិធីតឹងទារ ឬដោះស្រាយតាមផ្លូវច្បាប់ចំពោះបំណុលភ្នំរ៉ៃ ។

- បន្តរៀបចំយន្តការ និង ដាក់ចេញនូវវិធានការដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន សំរាប់ការគ្រប់គ្រង និង ប្រមូលចំណូលមិនមែនសារពើពន្ធ ។

- បន្តពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

- បន្តពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋឱ្យស្របទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ វិធានការពង្រឹងការប្រមូលចំណូលពីការជួល ឬ លក់អចលនទ្រព្យ រួមទាំងការពង្រឹងនីតិវិធីនៃការជួល និង ការចុះកិច្ចសន្យាផង ចំណូលពីសហគ្រាសសាធារណៈ តាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាស ចំណូលពីការលក់ទំនិញ និង ការផ្តល់សេវាសាធារណៈ និង ចំណូលពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។

- បន្តជំរុញការអនុវត្តប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និង ដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ ។

- បន្តជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការដាក់វិន័យ ចំពោះក្រសួង-ស្ថាប័ន ឬ មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលមិនព្រមបង់ចំណូលចូលរតនាគារ ឬ លួចលាក់ចំណូលទុកចាយនៅក្រៅបរិបថនៃថវិកាជាតិ និង ខុសនីតិវិធីច្បាប់ជាធរមាន ។

- បន្តអនុវត្តយ៉ាងហ្មត់ចត់ និង ជាប់ជាប្រចាំនូវសវនកម្ម និង អធិការកិច្ចលើការអនុវត្តន៍ កាតព្វកិច្ចបង់ចំណូលពុំមែនសារពើពន្ធរបស់គ្រប់ក្រសួង-ស្ថាប័ន និង សហគ្រាសសាធារណៈដែលមានការពាក់ព័ន្ធ ។

ខ- ការអនុវត្តន៍ចំណាយថវិកា

៩- ដើម្បីធានាដល់ការអនុវត្តន៍ថវិកាឆ្នាំ ២០០៧ ប្រកបដោយប្រសិទ្ធភាព និង សំរេចបានតាមគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ការគ្រប់គ្រងចំណាយត្រូវបន្តពង្រឹងបន្ថែមទៀត ជាពិសេសត្រូវពង្រឹងការគោរពច្បាប់ហិរញ្ញវត្ថុ និង ការគោរពអោយបានដាច់ខាតនូវវិន័យថវិកាទាំង ១១ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការអនុវត្តន៍អភិបាលកិច្ចល្អក្នុងការអនុវត្តន៍ថវិកា និង ការគ្រប់គ្រងថវិកា ជាពិសេស ការអនុវត្តន៍ឱ្យបានហ្មត់ចត់នូវរាល់ការកែលំអនៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

ខ.១- *ការរៀបចំ និង ការអនុវត្តន៍កម្មវិធីចំណូល- ចំណាយ*

១០- ដើម្បីអោយការអនុវត្តន៍ថវិកាប្រកបដោយភាពជឿទុកចិត្តបាន និង ប្រព្រឹត្តទៅដោយរលូនជាពិសេស ដើម្បីធានាការឆ្លើយតបទៅនឹងតំរូវការចំណាយជាក់ស្តែង ទាន់ពេលវេលា និង ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំគំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសសំរាប់រយៈពេលពេញ ១ ឆ្នាំ ដែលមានបែងចែកលំអិតទៅតាមខែ ដោយឈរលើមូលដ្ឋាននៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីពិនិត្យ និង វាយតំលៃ ដោយផ្អែកទៅលើអាទិភាពតំរូវការ និង លទ្ធផលចំណូល-ចំណាយជាក់ស្តែង ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសំរាប់ការអនុវត្តន៍ ។ ដោយឡែក មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវផ្ញើទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមួយច្បាប់

ដើម្បីធ្វើការបូកសរុប ហើយផ្ញើមកនាយកដ្ឋានថវិកា សំរាប់ការរៀបចំកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាស និង ផ្ញើទៅក្រសួង- ស្ថាប័ន តាមខ្សែបណ្ដោយរបស់ខ្លួនមួយច្បាប់ សំរាប់ការគ្រប់គ្រង និង តាមដានការអនុវត្តន៍ ។

១១- ដើម្បីឱ្យនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំឱ្យបានល្អ និង ត្រឹមត្រូវនូវការបែងចែកឥណទានថវិកាតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស និង អនុវត្តឱ្យបានសំរេចនូវការអនុវត្តន៍ចំណូល- ចំណាយថវិកាតាមទិសដៅរបស់រាជរដ្ឋាភិបាល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យបានហ្មឹងម៉ាត់នូវនីតិវិធីដូចខាងក្រោមៈ

- នៅរៀងរាល់ថ្ងៃទី ២០ នៃខែនាចុងត្រីមាសនីមួយៗ នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តន៍កម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកន្លងទៅ និង គំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសបន្ទាប់ ។

- នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត- ក្រុង ត្រូវផ្ញើរបាយការណ៍អំពីការអនុវត្តន៍ចំណូល- ចំណាយប្រចាំខែ មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុអោយបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ។

- នៅរៀងរាល់ថ្ងៃទី ២៥ នៃខែនាចុងត្រីមាសនីមួយៗ នាយកដ្ឋានថវិកាត្រូវកោះប្រជុំពិភាក្សា ជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិការដ្ឋសំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល- ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើប្រកាសប្រគល់កម្មវិធីចំណូល- ចំណាយសំរាប់ត្រីមាសបន្ទាប់ តាមជំពូកថវិកាក្នុងកំរិតឥណទានអតិបរមាជូនដល់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ដោយចម្លងជូននាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ និង អភិបាលខេត្ត- ក្រុង ។

- អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច និង រតនាគារជាតិ ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និង ត្រូវបើកជាសាច់ប្រាក់ តែនៅក្នុងកំរិតនៃកម្មវិធីប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់សុំបើកផ្ដល់បន្ថែម សាមុីអង្គភាពត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើប្រកាសផ្ដល់កម្មវិធីបន្ថែម នៅក្នុងក្របខ័ណ្ឌឥណទានថវិកាដែលមិនទាន់បែងចែកទៅក្នុងកម្មវិធីចំណាយ ។

• រតនាគារជាតិត្រូវបញ្ជូនមកនាយកដ្ឋានថវិកា នូវរបាយការណ៍ទូទាត់ប្រចាំថ្ងៃ របាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុប ចំណូល ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតំលៃនូវសភាពការណ៍អនុវត្ត ធៀបនឹងខែមុន ត្រីមាសមុន នៃឆ្នាំនេះ និង ប្រៀបធៀបទៅនឹងខែ ត្រីមាសដូចគ្នានៃឆ្នាំមុន ។

• រតនាគារខេត្ត-ក្រុងត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស និង ដើម្បីមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើរបាយការណ៍ផ្ញើមកនាយកដ្ឋានថវិកា ។

ខ.២- ការផ្តល់ធានាចំណាយ

• ការផ្តល់ធានាចំណាយ ត្រូវអនុវត្តទៅតាមប្រភេទចំណាយបីដូចខាងក្រោម៖

- ***ចំណាយបៀវត្ស*** ពុំតំរូវអោយមានធានាចំណាយទេ លើកលែងតែក្រសួងការពារជាតិដែលត្រូវសុំធានាចំណាយ ។
- ***ចំណាយដែលមិនតំរូវអោយអនុវត្តនិតិវិធីលទ្ធកម្មសាធារណៈ និង ចំណាយដែលមានរបបកំណត់ច្បាស់លាស់*** ពុំតំរូវអោយមានការសុំធានាចំណាយទេ ។
- ***ចំណាយដែលតំរូវអោយអនុវត្តនិតិវិធីលទ្ធកម្មសាធារណៈ*** តំរូវអោយមានការសុំធានាចំណាយយ៉ាងតិចមួយឆមាសម្តង ទាំងថវិកាតាមកម្មវិធី និង ថវិកាមិនមែនកម្មវិធី ។

• ចំពោះប្រភេទចំណាយដែលមិនតំរូវអោយមានការសុំធានាចំណាយ អាណាប័កត្រូវធ្វើអាណត្តិសុំទូទាត់តែម្តង ដោយមានភ្ជាប់មកជាមួយនូវឯកសារ និង លិខិតយុត្តិការគ្រប់គ្រាន់ស្របទៅតាមនីតិវិធីទូទាត់ ។

• មិនត្រូវអនុញ្ញាតឱ្យមានការធានាចំណាយ និង ការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិនបើគ្មានការស្នើសុំជាលាយលក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ ។

• មិនត្រូវធ្វើការធានាចំណាយ ប្រសិនបើគ្មានឥណទានថវិកានៅសល់ទំនេរ ត្រូវធ្វើការធានាចំណាយទៅតាមឥណទានថវិកាដែលមាន ។

• មិនត្រូវផ្តល់ធានាចំណាយអោយលើសពីឥណទានថវិកាដែលមានលក្ខណៈកំរិតកំណត់ ។

• មិនត្រូវផ្តល់ធានាចំណាយទៅលើការអនុវត្តន៍នូវសកម្មភាព ដែលនាំអោយមានការជ្រើសរើសបុគ្គលិកថ្មី ឬ បុគ្គលិកជាប់កិច្ចសន្យា នៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

• មិនត្រូវលើកសំណើចំណាយបន្ថែមប្រសិនបើគ្មានការសន្សំសំចៃពីខ្ទង់ចំណាយដទៃមកជំនួស ។

ខ.៣- *ការធ្វើលទ្ធកម្មសាធារណៈ*

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយផ្អែកលើតម្រូវការជាក់ស្តែង និង គោរពទៅតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្ម) ដើម្បីពិនិត្យ និង ផ្តល់ការឯកភាព ។

• ការធ្វើលទ្ធកម្មសាធារណៈត្រូវអនុវត្តន៍អោយបានទៀងទាត់ និង ទៅតាមប្រតិទិន ដែលបានកំណត់នៅក្នុងផែនការលទ្ធកម្ម ដែលបានឯកភាពដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការធ្វើលទ្ធកម្មដែលមិនស្ថិតនៅក្នុងផែនការលទ្ធកម្មនឹងមិនត្រូវបានទទួលស្គាល់ និង មិនធ្វើការទូទាត់ជូនទេ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវផ្ញើរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តន៍លទ្ធកម្ម រួមទាំងទិន្នន័យនៃកិច្ចសន្យា និង ការងារវិសហមជ្ឈការ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយបានទៀងទាត់ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគោរពអោយបានហ្មត់ចត់ ទៅតាមអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការរៀបចំផែនការលទ្ធកម្ម និង បទបញ្ញត្តិផ្សេងៗទៀតស្តីពីលទ្ធកម្មសាធារណៈ ។

• តំលៃសរុបនៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសពីឥណទានថវិកាដែលបានផ្តល់ការធានាចំណាយ ឬ ចំនួនទឹកប្រាក់ដែលបានយល់ព្រមផ្តល់មុនបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់ឡើយ ។

• មិនអនុញ្ញាតិឱ្យធ្វើការប្រគល់ទទួល ទំនិញ សំណង់ ឬ សេវា ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់ និង ចាំបាច់បំផុតសំរាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តំលៃ រយៈពេលផ្គត់ផ្គង់ ឬ សាងសង់ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។

• ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការផ្លាស់ប្តូរបញ្ចីប៉ាន់តំលៃ ឬ លក្ខណៈបច្ចេកទេសនៃ ទំនិញ សំណង់ ឬ សេវា ខុសពីឧបសម្ព័ន្ធនៃកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយល័ក្ខអក្សររបស់ភាគីទាំងពីរ និង មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

• ក្នុងករណីការងារដែលទទួលអនុវត្តដោយអង្គភាពរដ្ឋ ការទូទាត់ត្រូវរក្សាចំនួនទឹកប្រាក់ ១០% នៃតំលៃសរុបរបស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់ រហូតដល់ផុតរយៈពេលធានាគុណភាព ទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។

១.៤ - ការទូទាត់ និង ការបើកផ្តល់

- គ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ ត្រូវគោរពទៅតាមនិតិវិធី និង បទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ និង ការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេស ត្រូវរៀបចំសំណើសុំធ្វើការទូទាត់ទៅតាមលំដាប់លំដោយនៃកម្មវិធីចំណាយប្រចាំខែ អោយបានទៀងទាត់ ។
- មិនត្រូវអនុញ្ញាតឱ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសំរេចដោយឡែក ។
- ត្រូវធ្វើការទូទាត់ និង បញ្ចេញអាណត្តិបើកប្រាក់ ទៅតាមកម្មវិធីចំណូល- ចំណាយដែលបានកំណត់។
- មិនត្រូវអនុវត្តចំណាយ និង មិនត្រូវទូទាត់ជូនចំពោះចំណាយណាដែលគ្មានលិខិតយុត្តិការគ្រប់គ្រាន់។
- មិនត្រូវធ្វើអាណត្តិបើកប្រាក់ និង មិនត្រូវបញ្ជូនអាណត្តិបើកប្រាក់នោះទៅរតនាគារជាតិបានឡើយប្រសិនបើលិខិតយុត្តិការផ្លូវការមានលក្ខណៈមិនគ្រប់គ្រាន់ ។
- អាចផ្តល់ថវិកាបុរេប្រទានបាន តែក្នុងករណីចាំបាច់ជាបន្ទាន់ ហើយមានឥណទានសល់ទំនេរសំរាប់ចេញអាណត្តិទូទាត់បានក្រោយពីប្រតិបត្តិការចំណាយរួច ។
- អាចផ្តល់មូលនិធិជួសជុល-ថែទាំផ្លូវថ្នល់បាន លុះត្រាតែមានឥណទានសល់ទំនេរនៅក្នុងគណនីមូលនិធិ ។
- ការចេញអាណត្តិទូទាត់ ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល ដែលបានកំណត់នៅក្នុងកិច្ចសន្យា ។ ក្នុងករណីតម្លៃកិច្ចសន្យាមានចំនួនទឹកប្រាក់ច្រើនដល់រាប់ពាន់លានរៀលនោះ ការចេញអាណត្តិទូទាត់ត្រូវធ្វើឡើងជាច្រើនជំហានទៅតាមលទ្ធភាពនៃសាច់ប្រាក់ ។

១២- ទន្ទឹមនឹងការអនុវត្តន៍ចំណាយទៅតាមកម្មវិធីចំណូល- ចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ ត្រូវផ្តល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំ មានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជំងឺ ការប្រាក់ សងបំណុល ទឹក ភ្លើង ទូរស័ព្ទ វិភាគទានឱ្យអង្គការអន្តរជាតិនានា និង ចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តវិធានការមួយចំនួន ក្នុងគោលបំណងត្បិតត្បៀត សន្សំសំចៃលើចំណាយសំរាប់កិច្ចដំណើរការរបស់ក្រសួង-ស្ថាប័ន ជាពិសេសចំណាយលើការប្រើប្រាស់សំភារៈការិយាល័យ ប្រេងឥន្ធនៈ ទឹក ភ្លើង ទូរស័ព្ទ និង ចំណាយផ្សេងៗទៀតដែលមិនសូវចាំបាច់ ។

១៣- ដើម្បីឱ្យការអនុវត្តន៍ចំណាយថវិការដ្ឋប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្តុំចំណាយច្រើននៅចុងឆ្នាំ និង ម្យ៉ាងវិញទៀត ដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញនៅតាម

ខេត្ត-ក្រុង ឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និង អនុវត្តវិធីសាស្រ្តលទ្ធកម្មសាធារណៈដូចតទៅ÷

- រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និង ការផ្ទេរឥណទានថវិកាជូនអភិបាលខេត្ត-ក្រុង ដើម្បីឱ្យមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត- ក្រុង អាចមានលទ្ធភាពអនុវត្តនូវនីតិវិធីចំណាយបានទាន់ពេលវេលា ។
- ចំណាយថវិកាដ្ឋក្នុងការទិញសំភារៈ ជួលសេវា ជួសជុល និង សាងសង់ ត្រូវតែអនុវត្តឱ្យបានហ្មឹងម៉ាត់តាមគោលការណ៍ និង និតិវិធីលទ្ធកម្មសាធារណៈ ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃសាធារណៈ ត្រូវប្រញាប់ប្រញាល់លើកសំណើសុំគោលការណ៍ធានាចំណាយឆមាស អោយបានទាន់ពេលវេលា មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ឱ្យបាននៅដើមឆ្នាំ និង ដើមឆមាស ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។ កន្លងមក សាមីក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ ដែលជាហេតុបណ្តាលឱ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំនាំឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយសំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ មិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែឥណទានថវិកាដែលមានកំណត់នៅក្នុងសៀវភៅថវិកាតែប៉ុណ្ណោះ ប៉ុន្តែកម្មវិធីចំណាយត្រូវតែជាក់ស្តែង និង សុក្រិត ព្រោះវាជាមូលដ្ឋានសំរាប់ការរៀបចំផែនការសាច់ប្រាក់សំរាប់ការបើកផ្តល់ ។

១.៥ - *ការអនុវត្តន៍បៀវត្ស ប្រាក់បំណាច់ និង កន្ទ្រាមអាទិភាព*

១៤- ចំពោះចំនួនក្របខ័ណ្ឌ និង ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវតែពិនិត្យអនុវត្តតាមព្រះរាជក្រឹត្យលេខ នស/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់ក្នុងវិស័យអប់រំ អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និង ដាក់អោយដំណើរការកម្មវិធីកន្ទ្រាមអាទិភាព អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ អនុក្រឹតលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការកែសំរួល ការអនុវត្តន៍ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦ ស្តីពីការបន្ថែមបៀវត្សជូនកងយុទ្ធពលខេមរៈភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាព ពលកម្ម និង យុទ្ធជនពិការ អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ធ្នូ

ឆ្នាំ ២០០៦ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល និង តារាងទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធពតិមានវិទ្យាដែលចេញដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង-ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និង គ្រោងបៀវត្សនៅក្រសួង-ស្ថាប័នដែលបានផ្ទេរចូលអោយទាន់ពេលនៅឆ្នាំបន្ទាប់ ។ ចំពោះការអនុវត្តន៍កន្សោមអាទិភាព ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្តក្រុងទាំងអស់ ក្រោយពីបានទទួលសេចក្តីសំរេចពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើសំណើសុំថវិកាមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាបន្ទាន់ ដើម្បីអោយការអនុវត្តន៍កន្សោមអាទិភាពនេះប្រព្រឹត្តទៅដោយរលូន និង មានប្រសិទ្ធភាព ។ ចំពោះកម្មវិធីកន្សោមអាទិភាពដែលត្រូវអនុវត្តបន្ត ត្រូវធ្វើសំណើសុំថវិកាមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៧ ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍នៃការអនុវត្តន៍កម្មវិធីកន្សោមអាទិភាពកន្លងមក និង សេចក្តីសំរេចរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ខ.៦ - *ការផ្ទេរចលនាឥណទានថវិកា*

១៥- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ នៅដើមត្រីមាសទី២ ក្រោយពីការអនុវត្តន៍ត្រីមាសទី១ ចប់សព្វគ្រប់មក ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សំរេចជាមុនសិន ទើបលើកសំណើសុំខ្ទង់ចំណាយនោះបាន ។ បើក្រសួងស្ថាប័ន មានសំណូមពរ ផ្តល់ឥណទានបន្ថែម ដូចជាចំណាយដំណើរការរដ្ឋបាល សំភារៈ ការជួសជុលតូច ការសាងសង់ និង ទុព្វសំភារៈ ។ល។ ទៅឱ្យមន្ទីរជំនាញរបស់ខ្លួននៅខេត្ត-ក្រុង នោះគឺត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន ។

III. ការតាមដានការអនុវត្តន៍ថវិកា និង ការធ្វើរបាយការណ៍

១៦- ដើម្បីបង្កើនគណនេយ្យភាព និង ការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈជាពិសេស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តន៍ថវិកា គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ត្រូវធ្វើការតាមដានការអនុវត្តន៍ថវិការបស់ខ្លួនជាប្រចាំ និង ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ហើយផ្ញើរមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបានទៀងទាត់ ទៅតាមគំរូដែលបានផ្ញើជូន និង នៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍ប្រចាំខែមុន ត្រូវផ្ញើរមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់

- របាយការណ៍ប្រចាំត្រីមាសមុន ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែ នៅដើមត្រីមាសបន្ទាប់
- របាយការណ៍ឆមាសទី១ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មិថុនា
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨

IV. វិធានការរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា

១៧- នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តន៍ថវិកានឹងមិនអាចសំរេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតំរូវក្នុងករណីចាំបាច់ ។
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនអនុញ្ញាតិអោយមានការបោះផ្សាយអាណត្តិតំកល់ទុកសំរាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ ២០០៧ របស់យើងអោយសំរេចបានជោគជ័យតាមការគ្រោងទុក ដើម្បីបំរើអោយការអនុវត្តន៍ **យុទ្ធសាស្ត្រចតុកោណ** របស់សម្តេចនាយករដ្ឋមន្ត្រី ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** និង ឆ្លើយតបទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដើម្បី ***កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន*** ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឈន់

ចំលងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័តមាន"
- គ្រប់ក្រសួង- ស្ថាប័ន
- គ្រប់ខេត្ត- ក្រុង
  "ដើម្បីអនុវត្ត"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០១១......សហវ.....

រាជធានី ភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

សេចក្តីណែនាំ

ស្តីពី

ការបំពេញបន្ថែមលើអាណត្តិបើកប្រាក់ ការកត់ត្រាអចលកម្មកំពុងដំណើរការ ការបើកប្រាក់វិជ្ជមានបុរេប្រទាននៅដើមការិយបរិច្ឆេទ និង ការកត់ត្រា ចំណាយថវិកាតាមកម្មវិធីទាក់ទងមាតិកាគណនីថ្មី

១-ការបំពេញលើអាណត្តិបើកប្រាក់

ដើម្បីអោយមានការឯកភាពគ្នាលើការកត់ត្រាលើអាណត្តិបើកប្រាក់ សំរាប់ថវិការដ្ឋ ថវិកា ខេត្ត-ក្រុង និង ថវិកា ឃុំ សង្កាត់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមធ្វើការណែនាំអនុវត្តដូចមានខ្លឹមសារខាងក្រោមនេះ :

ក-អាណត្តិបើកប្រាក់ដែលអត្ថគាហកត្រូវបើកជាសាច់ប្រាក់ពីបេឡារតនាគារ អ្នកទទួលប្រាក់ត្រូវចុះហត្ថលេខានៅភាគខាងក្រោមនៃអាណត្តិបើកប្រាក់ (ត្រង់ " ដើម្បីនិមុត្តិ ឬ អ្នកទទួលប្រាក់ ") ។

ខ-ក្នុងករណីដែលការទូទាត់ដោយមូលប្បទានប័ត្រអត្ថគាហកត្រូវចុះហត្ថលេខានៅភាគខាងក្រោម នៃ អាណត្តិបើកប្រាក់ (ត្រង់ " ដើម្បីនិមុត្តិ ឬ អ្នកទទួលប្រាក់ ") ដោយមានការបញ្ជាក់នូវលេខមូលប្បទានប័ត្រ និងចំនួនទឹកប្រាក់ ។

គ-ករណីទូទាត់ដោយបង្វែរ អត្ថគាហកពុំចាំបាច់ចុះហត្ថលេខានៅភាគខាងក្រោមនៃអាណត្តិបើកប្រាក់ (" ត្រង់ដើម្បីនិមុត្តិ ឬ អ្នកទទួលប្រាក់ ") នោះទេ តែត្រូវមានសំណើរសុំផ្ទេរ ។

ឃ-ប្រធានរតនាគារត្រូវចុះហត្ថលេខា និងបោះត្រានៅលើដីកាអមនៃការបញ្ចេញអាណត្តិបើកប្រាក់ទន្ទឹមនឹងការចុះហត្ថលេខាលើអាណត្តិបើកប្រាក់ ។ ដីកាអមនៃការបញ្ចេញអាណត្តិបើកប្រាក់ត្រូវមានការបញ្ជាក់អំពីចំនួនទឹកប្រាក់ចំណាយថវិកាដុល ទឹកប្រាក់បានកាត់ទុក និងទឹកប្រាក់ពិតត្រូវទូទាត់ ឬត្រូវបើកផ្តល់ ។ ដីកាអមនៃការបញ្ចេញអាណត្តិបើកប្រាក់ត្រូវប្រគល់ជូនទៅសាមីអង្គភាពជាអ្នកបោះផ្សាយអាណត្តិបើកប្រាក់វិញចំនួនមួយច្បាប់ ។

២-ការប្រើប្រាស់អនុគណនីសំរាប់អចលកម្មកំពុងដំណើរការ

ក្នុងពេលគ្រោងឥណទានថវិកាសំរាប់ចំណាយលើអចលកម្មកំពុងដំណើរការ ពុំទាន់បានបំបែកពីឥណទានថវិកាសំរាប់អចលកម្មផលិត សាងសង់រូចរាល់ជាស្ថាពរ ការកត់ត្រាត្រូវប្រើអនុគណនីដូចគណនីអចលកម្មពាក់ព័ន្ធ ជំនួសគណនីលេខ

២៣១ និង គណនីលេខ ២៣២ ដោយបន្ថែមលេខកូដដូចតទៅ :

ក- សំរាប់ការកត់ត្រាអចលកម្មកំពុងដំណើរការត្រូវបន្ថែមលេខ ០៣ បន្ទាប់ពីលេខគណនីអចលកម្ម ។

ឧទាហរណ៍ : ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់មិនទាន់រួចរាល់ ត្រូវប្រើអនុគណនីលេខ ២១៤១.០៣ ។

ខ- សំរាប់អចលកម្មដែលបានផលិត សាងសង់រួចរាល់ជាស្ថាពរត្រូវបន្ថែមលេខ ០៤ បន្ទាប់ពីលេខគណនីអចលកម្ម ។

ឧទាហរណ៍ : ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់សាងសង់រួចរាល់ ត្រូវប្រើអនុគណនីលេខ ២១៤១.០៤ ។

៣-ការបើកប្រាក់រជ្ជទេយ្យបុរេប្រទាននៅដើមការិយបរិច្ឆេទ

ក្នុងពេលការរៀបចំប្រកាស និង ដីកាស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទានពុំអាចធ្វើបាននៅខែ មករា រតនាគារត្រូវដំណើរការបើកប្រាក់រជ្ជទេយ្យលើកទី ១ ជូនក្រសួង មន្ទីរ អង្គភាព ដោយផ្អែកលើមូលដ្ឋានកំរិតកំណត់រជ្ជទេយ្យ (ជុំបង្វិល) ឆ្នាំចាស់ ។ ចាប់ពីឆ្នាំ ២០០៧ ក្រសួង មន្ទីរ អង្គភាព ត្រូវធ្វើអាណត្តិនិយ័ត្តកម្មទៅតាមមាតិកាថវិកាថ្មី ។

៤-ការប្រើប្រាស់អនុគណនីសំរាប់តាមដានការអនុវត្តន៍ថវិកាតាមកម្មវិធីនៅរតនាគារ

ក-ការតាមដានការអនុវត្តន៍ចំណាយថវិកាតាមកម្មវិធីនីមួយៗជាភារកិច្ចរបស់នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា សាមីក្រសួង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សាមីមន្ទីរ ។

ខ- ក្រសួង ស្ថាប័ន មន្ទីរ និង អង្គភាព ចំណាយថវិកាតាមកម្មវិធីត្រូវបោះត្រាសំគាល់ " ថវិកាតាមកម្មវិធី " នៅលើអាណត្តិបើកប្រាក់ ។

គ-ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាព ដែលបោះផ្សាយអាណត្តិបើកប្រាក់ទាក់ទងចំណាយថវិកាវិនិយោគ ត្រូវបោះត្រាសំគាល់ " អចលកម្មកំពុងដំណើរការ " នៅលើអាណត្តិបើកប្រាក់សំរាប់ការសាងសង់ ការផលិតអចលកម្ម ដែលពុំទាន់បានបញ្ចប់ជាស្ថាពរនៅក្នុងឆ្នាំអនុវត្តថវិកា ។

ឃ-រតនាគារត្រូវធ្វើការតាមដានចំណាយថវិកាលើគណនី ឬ អនុគណនី ដោយចែកដាច់ពីគ្នារវាងថវិកាមិនមែនកម្មវិធី និង ថវិកាតាមកម្មវិធី ។

- លេខគណនី ឬអនុគណនី ចំណាយថវិកាមិនមែនកម្មវិធី គឺត្រូវបន្ថែមលេខ **០១** ពីក្រោយលេខគណនី ឬអនុគណនី ចំណាយថវិកាពាក់ព័ន្ធ ។

ឧទាហរណ៍ : ចំណាយថវិកាបេសកកម្មក្នុងប្រទេស មិនមែនកម្មវិធី ត្រូវកត់ត្រាទៅក្នុងអនុគណនីលេខ ៦២៤២.**០១**

- លេខគណនី ឬ អនុគណនី ចំណាយថវិកាតាមកម្មវិធី គឺត្រូវបន្ថែមលេខ **០២** ពីក្រោយលេខគណនី ឬអនុគណនី ចំណាយថវិកាពាក់ព័ន្ធ ។

ឧទាហរណ៍ : ចំណាយថវិកាបេសកកម្មក្នុងប្រទេស តាមកម្មវិធី ត្រូវកត់ត្រាទៅក្នុងអនុគណនី លេខ ៦២៤២.**០២** ។

ង- រតនាគារត្រូវរៀបចំរបាយការណ៍ចំណាយថវិកាចំពោះក្រសួងដែលមានថវិកាតាមកម្មវិធី ដោយចែកចេញជាចំណាយ ចំណាយថវិកាសរុប ចំណាយថវិកាមិនមែនកម្មវិធី និង ចំណាយថវិកាតាមកម្មវិធី ។ ដោយឡែកចំពោះក្រសួងដែលពុំមានថវិកាតាមកម្មវិធី ត្រូវធ្វើរបាយការណ៍ចំណាយថវិកាសរុបតែមួយ ។

ច- ការកត់ត្រាចំនួនទឹកប្រាក់បំណុលត្រូវសងទៅអ្នកផ្គត់ផ្គង់ ឬត្រូវបើកផ្តល់ជូនទៅក្រសួង មន្ទីរ អង្គភាព រតនាគារ ត្រូវប្រើលេខសំគាល់ដូចខាងក្រោមនេះ :

- លេខ **០១** បន្ទាប់ពីលេខអនុគណនី សំរាប់តាមដានបំណុលមិនមែនកម្មវិធី ។

ឧទាហរណ៍ ១ : ចំនួនទឹកប្រាក់បេសកកម្មក្នុងប្រទេសត្រូវសងទៅក្រសួងសុខាភិបាល មិនមែនតាមកម្មវិធីមានលេខគណនី ៤២២..១.១០.**០១**.១២ (ក្រសួងសុខាភិបាល) ។

ឧទាហរណ៍ ២ : ចំនួនទឹកប្រាក់បេសកកម្មក្នុងប្រទេសត្រូវសងទៅមន្ទីរសុខាភិបាល មិនមែនតាមកម្មវិធី មានលេខគណនី ៤២២.២០.**០១**.១២ (មន្ទីរសុខាភិបាល) ។

- លេខ **០២** បន្ទាប់ពីលេខអនុគណនី សំរាប់តាមដានបំណុលតាមកម្មវិធី ។

ឧទាហរណ៍ ១ : ចំនួនទឹកប្រាក់បេសកកម្មក្នុងប្រទេសត្រូវសងទៅក្រសួងសុខាភិបាល តាមកម្មវិធី មានលេខគណនី ៤២២.១.១០.**០២**.១២ (ក្រសួងសុខាភិបាល) ។

ឧទាហរណ៍ ២ : ចំនួនទឹកប្រាក់បេសកកម្មក្នុងប្រទេសត្រូវសងទៅមន្ទីរសុខាភិបាល តាមកម្មវិធី មានលេខគណនី ៤២២.២០.**០២**.១២ (មន្ទីរសុខាភិបាល) ។

ឆ- នៅលើតារាងតុល្យភាពគណនីរបស់រតនាគារត្រូវចែកដាច់ពីគ្នារវាងគណនីបំណុលត្រូវសងសំរាប់ថវិកាមិនមែនកម្មវិធី និងគណនីបំណុលត្រូវសងសំរាប់ថវិកាតាមកម្មវិធី ឯគណនីចំណាយថវិកាមិនមែនតាមកម្មវិធី និងគណនីចំណាយថវិកាតាមកម្មវិធីគឺត្រូវប្រើគណនីរួមគ្នា ។

៥_ការប្រើប្រាស់អនុគណនី ការសង និង ការបង្វិលទិញសំរាប់សំណេះចំណាយ

ក- រតនាគារត្រូវបង្កើតជាអនុគណនីបន្តនៃអនុគណនី ការសង និង ការបង្វិលវិញ (លេខ ៦៤១៩ ៦៤២៩ , ៦៤៣៩ ៦៤៤៩ និង ៦៤៥៩) ដោយលំអិតទៅតាមប្រភេទគណនីចំណាយថវិកាដែលពាក់ព័ន្ធ ។

ឧទាហរណ៍ : ការបង់សំណេះចំណាយ ប្រាក់បៀវត្សមូលដ្ឋាននៃបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ (លេខ ៦៤២១) ត្រូវកត់ត្រាទៅក្នុងអនុគណនីបន្ត ការសង និង ការបង្វិលវិញនូវប្រាក់បៀវត្សមូលដ្ឋាន (លេខ ៦៤២៩.១) ។

ខ- ការបង់សំណេះចំណាយ ត្រូវធ្វើការកត់ត្រាបន្ថយចំណាយក្នុងគ្រានៅលើសលាកប័ត្រតាមដានការប្រើប្រាស់ឥណទានថវិកា ។ សំណេះចំណាយឆ្នាំមុនដែលបានបង់ក្នុងការិយបរិច្ឆេទកំពុងអនុវត្ត ក៏ ត្រូវកត់ត្រាបន្ថយចំណាយក្នុងឆ្នាំកំពុងអនុវត្តទៅក្នុងអនុគណនីបន្ត ការសង និង ការបង្វិលវិញ ដូចសំណេះចំណាយក្នុងឆ្នាំដែរ គឺពុំកត់ត្រាទៅក្នុងគណនីចំណូលថវិកាទេ ។

គ-នៅដំណាច់ឆ្នាំ មុនការគណនាលទ្ធផលនៃការិយបរិច្ឆេទ រតនាគារត្រូវផ្ទេរសមតុល្យឥណទាយីនៃអនុគណនីបន្ត ការសង និងការបង្វិលវិញ ទៅអនុគណនីចំណាយថវិកាដែលពាក់ព័ន្ធ ។ បន្ទាប់មកទើបផ្ទេរសមតុល្យពិតនៃអនុគណនីចំណាយថវិកាទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានអង្គភាពដែលពាក់ព័ន្ធ ចាត់ចែងអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ខេត្ត-ក្រុង
- គ្រប់នាយកដ្ឋាន អង្គភាពនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  " ដើម្បីអនុវត្ត "
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៥៧៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០៦

នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានិតិបុគ្គលពេញ លក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌ ដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **ឡាថេល ខូ អិលធីឌី** **LATELZ CO., LTD.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 3171 / 06 E ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា	: សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោក WONG LOCK KAY
៣- ដើមទុនក្រុមហ៊ុន	: ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ៥ C_1 ផ្លូវលំ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ទិញ លក់ ជួល ជួសជុល បរិធានទូរស័ព្ទ - ផ្តល់សេវាទាក់ទងតាមទូរស័ព្ទ ហ្វាក់ -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ - ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូនៈ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្មៈ រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនអំពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និង សុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

ការ

ចំ ស៊ីថន

ចម្លងជូន :

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណៈការ និង ដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៤៣ **ពណ.នតក**

ភ្នំពេញថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៦

សេចក្តីជូនដំណឹង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១-	នាមករណ៍របស់ក្រុមហ៊ុន	: **វ៉ាសាប៊ី ហូលឌីង អិលធីឌី** **WASABI HOLDING LTD.**
	អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: **Co. 3169/06E** ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៦
	មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២-	អភិបាលក្រុមហ៊ុន	: លោក WONG TOW FOCK " គតិយជន " ប្រធានក្រុមប្រឹក្សាភិបាល លោក DATE TOMOYUKI អភិបាល
៣-	ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤-	ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ១៦ ផ្លូវលេខ ១៥២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។
៥-	កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្តវីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ [?] -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។ [?]
៦-	ថិរវេលា	: ៩៩ ឆ្នាំ [?]

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

កឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៨៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ជូលីណា ក្លឹប ខូ អិលធីឌី**
JULIANA CLUB Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3170/06E ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក WONG TOW FOCK " គតិយជន " ប្រធានក្រុមប្រឹក្សាភិបាល
លោក ONOZUKA KOJI អភិបាល
លោក DATE TOMOYUKI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៦ ផ្លូវលេខ ១៥២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាប[illegible]ទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌល[illegible]
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រសិប្បកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

គឹម_ស៊ីថន

<u>**ចំលងជូន**</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៦០៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១៧ ខែ ១០ ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុនដើម : **ធូរីស & ត្រេឌីង ខមភេនី លីមីធីត**
TOURIST & TRADING COMPANY LIMITED.

នាមករណ៍របស់សាខា : **សាខាក្រុមហ៊ុន " ធី & ធី (ខេមបូឌា) "**
Branch of " T & T (CAMBODIA) CO., LTD. "

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 355/06B** ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៦

២- នាយកសាខាក្រុមហ៊ុន : លោក **ហោង ម៉េកូល** " តតិយជន "

៣- ទីស្នាក់ការសាខា : ផ្ទះលេខ ១៦៣ ផ្លូវលេខ ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៤- កម្មវត្ថុអាជីវកម្ម : - ទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូន ផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស

៥- សញ្ជាតិក្រុមហ៊ុន : វៀតណាម

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ចាម ប្រសិទ្ធ

ចំលងជូន:

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ ✓
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៦៣២ ពណ.នតក

ភ្នំពេញថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦

និសសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តាកា ភេត្រូលៀម អ៊ីមផត អិចផត លីមីធីត**

TAKA PETROLEUM IMPORT EXPORT LIMITED

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9144/06 P** ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកឧកញ៉ា **សូ សុវណ្ណ** ប្រធានក្រុមប្រឹក្សាភិបាល

លោកជំទាវ **អៀវ បូផារី** អភិបាល

កញ្ញា **សូ លីកា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៣២.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៤៧ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលប្រេងឥន្ធនៈ និងឧស្ម័នគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម

-សេវារកការងារជូនពលរដ្ឋខ្មែរធ្វើការនៅក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ផ្លូវថ្នល់ អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋាន និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩៦៣.៤ ពណ.នតក

ភ្នំពេញថ្ងៃទី ១៧ ខែ ១០ ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេ អិន ខេ**

K N K Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9155//06P** ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ហូ សុវណ្ណរិកា** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ជា ផល្លួន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៨៥ ផ្លូវលេខ ១៥៥ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៦៣៥ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេប៊ីខឹស ត្រាវែល & ធួរ**

ABACUS TRAVEL & TOURS Co., Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9150/06P ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ម៉ៅ ឈារី**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ១៧០-១៥ Z ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : ទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់ស្រាវជ្រាវផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើការក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.រដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦៦៣៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **យឿក ស៊ុន អ៊ិនវេសមេន**
YUE SUN INVESTMENT Co.,Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3180/06E ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក LI WEIGUO
៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៨៦ ផ្លូវចោមចៅ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម- ពិសេសរោងចក្រផលិតស្បែកជើង អំបោះ សំភារៈប្រើប្រាស់ពីផ្លាស្ទិក ប្រអប់កាតុង និងស្លាក (STICKERS) គ្រប់ប្រភេទ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដូសផុលសំភារ: ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនិមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ទ្រឹង ស៊ីជិន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ